មករា - មីនា ២០១៦ | លេខ ០៣

CAMBODIA
RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

## រួមគ្នាលើកស្ទួយអង្ករកម្ពុជា



www.crf.org.kh / www.facebook.com/cambodiaricefederation

ចេញផ្សាយដោយ

**សហពន្ធ័ស្រូវអង្ករកម្ពុជា**

អាស័យដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧
អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី II
ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ៖ www.crf.org.kh
សារអេឡិចត្រូនិក៖ info@crf.org.kh
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហពន្ធ័ស្រូវអង្ករកម្ពុជា

ចូលរួមឧបត្ថម្ភដោយ

- Nikoline Investment Co., LTD
- ANZ ROYAL

## មាតិកា

ទំព័រទី

- **សាររបស់ឯកឧត្តម សុខ ពុទ្ធិវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា** ៣
- **សង្ខេបព្រឹត្តិការណ៍សំខាន់ៗរបស់សហព័ន្ធស្រូវអង្ករកម្ពុជា** ៤
  - វេទិកាស្រូវអង្ករកម្ពុជាលើកទី៥ ឆ្លុះបញ្ចាំងពីភាពជោគជ័យក្នុងវិស័យស្រូវអង្ករនៅកម្ពុជា ៤
  - កិច្ចប្រជុំចែករំលែកបទពិសោធន៍ និងព័ត៌មានរវាងអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករនៅខេត្តសៀមរាបនិងសហព័ន្ធស្រូវអង្ករកម្ពុជា ៦
  - កិច្ចប្រជុំពិភាក្សាការងារ ស្តីពីកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការ GIZ ៦
  - កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធស្រូវអង្ករកម្ពុជាលើកទី១១ ៦
  - កិច្ចប្រជុំពិភាក្សានិងពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ៨
  - ជំនួបប្រជុំរវាងអគ្គនាយកដ្ឋានពន្ធដារ និងសហព័ន្ធស្រូវអង្ករកម្ពុជា ៩
  - កិច្ចប្រជុំលើកទី ៦ របស់គណៈកម្មាធិការប្រតិបត្តិផ្នែកផលិតកម្មស្រូវ និងការកែច្នៃ (FMP-Exco) ៩
  - ដំណើរទស្សនកិច្ចទៅកាន់មូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ ដែលជាសមាជិកថ្មីរបស់សហព័ន្ធ ១០
  - លទ្ធផលសង្ខេប នៃកិច្ចប្រជុំក្រុមការងារទី៩ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កិច្ចប្រជុំនៃវេទិការាជរដ្ឋាភិបាល និងវិស័យឯកជន ក្រុមការងារស្រូវអង្ករ ១១
- **អំពីគណៈកម្មការទទួលបន្ទុកដោះស្រាយបញ្ហាប្រឈមបន្ទាន់** ១២
- **អំពីការងារស្រាវជ្រាវ និងគូសទីតាំងសមាជិកសហព័ន្ធ** ១៤
- **ការវិវត្តនៃស្ថានភាពនៃបញ្ហាប្រឈមនៃពូជ និងការដាំដុះស្រូវ** ១៥
- **ព័ត៌មានអំពីដៃគូអភិវឌ្ឍន៍ និងសមាជិកសំខាន់ៗ** ១៦
  - ស្វែងយល់អំពីកម្មវិធី អ៊ិម អូ ស៊ី ១០១ Incubator របស់ក្រសួងពាណិជ្ជកម្ម ១៦
  - ស្វែងយល់អំពី វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) និងបសិដ្ឋកម្មដំណាំស្រូវនៅកម្ពុជា ១៧
  - កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់(RED III) បានធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនង និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅក្នុងវិស័យស្រូវ/អង្ករខេត្តសៀមរាប ១៨
  - ការផ្លាស់ប្តូរពី កសិករ ទៅជាសេដ្ឋីស្រុកស្រែ ២០
  - ម្រេចកំពតជាទំនិញសម្គាល់ភូមិសាស្ត្រដំបូងនៅក្នុងតំបន់ ២០
- **សម្រង់អត្ថបទព័ត៌មានសំខាន់ៗដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុកពីខែមករា ដល់ ខែមីនា ឆ្នាំ២០១៦** ២១
- **អំពីសមាជិក ស.អ.ក** ២២
- **ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ** ២៤
- **ស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជា** ២៦

# សាររបស់ឯកឧត្តម សុខ ពុទ្ធីវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា



*ឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា*

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការសហការគាំទ្រ និងការចូលរួមវិភាគនូវគំនិត ចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃផ្សេងៗពី វាគ្មិន អ្នកជំនាញ និងអ្នកចូលរួមផ្សេងៗទៀត នៅក្នុងវេទិកាស្រូវអង្ករលើកទី៥ ដែលបានធ្វើអោយវេទិកានេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

នាពេលថ្មីៗនេះ ការប្រកួតប្រជែងកាន់តែខ្លាំងទាំងក្នុង និងក្រៅ បានធ្វើអោយសមាជិក សមាជិការបស់យើងរងនូវសំពាធយ៉ាងខ្លាំង ដែលធ្វើអោយសមាជិកខ្លះឈានដល់ការផ្អាក ឬឈប់នូវអាជីវកម្មរបស់ខ្លួន។ ឆ្លើយតបនឹងការប្រឈមនេះ សហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើការជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដើម្បីស្វែងរកនូវច្រកចេញណាមួយ ជូនដល់សមាជិករបស់យើង។ ជាមួយរាជរដ្ឋាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងនូវបញ្ហាប្រឈមរបស់សមាជិកកំពុងជួបប្រទះ តាមរយៈវេទិការាជរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីស្នើសុំការជួយអន្តរាគមន៍បន្ទាន់មួយរបស់រាជរដ្ឋាភិបាលក្នុងការរកដំណោះស្រាយ។ បញ្ហាប្រឈមដែលបានលើករួមមាន បញ្ហាទុនបង្វិល ឃ្លាំងស្តុក ការទប់ស្កាត់ការនាំចូលអង្ករខុសច្បាប់ ការពង្រឹងសមត្ថភាពប្រកួតប្រជែងតាមរយៈការកាត់បន្ថយថ្លៃដើម (អគ្គិសនី ពន្ធអាករលើតម្លៃបន្ថែម(VAT)លើអាជីវកម្មអង្ករក្នុងស្រុក បញ្ហាថ្លៃដឹកជញ្ជូន ជាដើម) ។ល។ ជាដំណោះស្រាយភ្លាមៗ រាជរដ្ឋាភិបាលបានយល់ព្រមក្នុងការបញ្ចុះពន្ធអាករលើតម្លៃបន្ថែមលើផលិតផលអង្ករដែលលក់ក្នុងស្រុកមកត្រឹម0% ហើយសន្យាក្នុងការពង្រឹងការប្រមូលពន្ធគយរបស់អង្ករនាំចូល និងចាត់វិធានការតឹងរឹងដើម្បីទប់ស្កាត់ការលាយបន្លំអង្ករណាមួយដែលធ្វើអោយការប្រកួតប្រជែងមានភាពមិនស្មើគ្នា។ តម្លៃអគ្គិសនីដែលពីមុនមានតម្លៃ ២៥សេនក្នុងមួយគីឡូវ៉ាត់ម៉ោង ត្រូវបានរដ្ឋកាត់បន្ថយ មកត្រឹម១៦.៧៥ សេន ក្នុងមួយគីឡូវ៉ាត់។

តែទោះបីជាយ៉ាងណា នៅមានបញ្ហាប្រឈមផ្សេងៗទៀត ដែលមិនទាន់ត្រូវបានដោះស្រាយបាននៅឡើយ។ សហព័ន្ធស្រូវអង្ករកម្ពុជា នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដើម្បីស្វែងរកដំណោះស្រាយ ដើម្បីពង្រឹងសមត្ថភាពការប្រកួតប្រជែងរបស់អង្ករកម្ពុជាអោយកាន់តែខ្លាំង និងចូលរួមលើកស្ទួយវិស័យនេះអោយកាន់តែលូតលាស់រីកចម្រើន។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦
ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា



**សុខ ពុទ្ធីវុធ**

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗរបស់សហព័ន្ធស្រូវអង្ករកម្ពុជា

## វេទិកាស្រូវអង្ករកម្ពុជាលើកទី៥ ឆ្លុះបញ្ចាំងពីភាពជោគជ័យក្នុងវិស័យស្រូវអង្ករនៅកម្ពុជា


ប្រធានស.អ.ក ទទួលពានកិត្តិយសពី **សម្តេចតេជោ**


តំណាងសហគមន៍សង្ការផលទទួលពានពី **សម្តេចតេជោ**





- គោលនយោបាយស្រូវអង្ករសម្រេចបានជាង ៨៧,៥០%នៃគោលដៅ
- វិស័យឯកជនបន្តរួមគ្នាដើម្បីរកគន្លឹះដោះស្រាយបញ្ហាប្រឈម

ការរៀបចំវេទិកាស្រូវអង្ករលើកទី៥រយៈពេលពីរថ្ងៃគឺនៅថ្ងៃទី២៤-២៥-២៦ ខែមករាឆ្នាំ២០១៦ កន្លងទៅនេះ ចំពេលដែលវិស័យស្រូវអង្ករមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជានោះទេ តែសម្រាប់ពិភពលោកទាំងមូលបានប្រឈមការលំបាកដ៏ខ្លាំង។ អ្នកពាក់ព័ន្ធនៅក្នុងវិស័យស្រូវអង្ករប្រមាណ ៧០០ នាក់ ដោយក្នុងនោះ មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ សហគមន៍កសិកម្ម ក្រុមហ៊ុននាំចេញអង្ករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនដឹកជញ្ជូន តំណាងដៃគូរអភិវឌ្ឍន៍ និស្សិតភ្ញៀវជាតិ និងអន្តរជាតិ បានចូលរួមវេទិកាស្រូវអង្ករកម្ពុជាលើកទី៥នេះ ដើម្បីទទួលព័ត៌មាន និង ពិភាក្សាលើបញ្ហាក្នុងវិស័យស្រូវអង្ករ។

**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសន្ទរកថាគន្លឹះបើកវេទិកាស្រូវអង្ករប្រចាំឆ្នាំនេះ ដោយបានគូសបញ្ជាក់នូវ បញ្ហាប្រឈមជាច្រើន ដែលកម្ពុជាកំពុងជួបប្រទះ បើទោះបីជាកម្ពុជាទំនងជាជោគជ័យក្នុងការអនុវត្តគោលនយោបាយស្រូវអង្ករ ដែលខ្លួនបានដាក់ចេញកាលពីខែសីហាឆ្នាំ២០១០។

**សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា គោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករដែលរាជរដ្ឋាភិបាលបានប្រកាសដាក់ចេញកាលពីឆ្នាំ២០១០ ដោយមានគោលដៅធំពីរ គឺ ទី១ ជំរុញការផលិតស្រូវឲ្យបានច្រើនជាង ៤លានតោន ដោយក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញ ត្រូវសម្រេចឲ្យបានយ៉ាងតិចមួយលានតោន និង ទី២ លើកកេរ្តិ៍ឈ្មោះអង្ករ កម្ពុជានៅលើឆាកអន្តរជាតិ។

**សម្តេច ហ៊ុន សែន** បានសន្និដ្ឋានជារួមថា «យើងសម្រេចគោលដៅទី២នេះ យ៉ាងត្រចះត្រចង់ ដោយកម្ពុជាបាននាំអង្ករទៅកាន់ទីផ្សារនានានៅលើពិភពលោក ជាង៦០ប្រទេស។ ជាមួយគ្នានេះ អង្ករកម្ពុជាត្រូវបានជាប់ចំណាត់ថ្នាក់ អង្ករឆ្ងាញ់បំផុតនៅលើពិភពលោកជាបន្តបន្ទាប់។ ចំណែក គោលដៅទី១ យើងសម្រេចបានប្រមាណពាក់កណ្តាល។ បរិមាណអតិរេកស្រូវ បានកើនពី៣.៥លានតោនក្នុងឆ្នាំ២០០៩ មកដល់ ៤.៧លានតោន នៅឆ្នាំ២០១៥។ ចំណែកគោលដៅនាំចេញ កម្ពុជាសម្រេចបាន ពាក់កណ្តាល ដោយនាំចេញអង្ករជាង៥៣ម៉ឺនតោននៅឆ្នាំ២០១៥ នៃគោលដៅ១លានតោន»។

**សម្តេច ហ៊ុន សែន** បានបញ្ជាក់ថា៖ «សរុបមក យើងអាចសម្រេចបានជាង ៨៧,៥០%នៃគោលដៅ ដែលយើងបានដាក់ចេញ ដែលអាចចាត់ទុកថា ជាលទ្ធផលល្អប្រសើរគួរជាទីមោទនៈ»។

ក្នុងវេទិកាស្រូវអង្កររយៈពេលពីរថ្ងៃប្រកបដោយភាពមមាញឹកនិងកម្មវិធីដ៏ច្រើន សហព័ន្ធស្រូវអង្ករកម្ពុជា បានបង្ហាញអំពីទិសដៅអភិវឌ្ឍន៍វិស័យស្រូវអង្ករនៅកម្ពុជា តាមរយៈកម្មវិធីកិច្ចពិភាក្សាពិគ្រោះយោបល់ទៅលើប្រធានបទសំខាន់ៗចំនួន ៦ រួមមាន៖ ១)ពូជ ២)ផលិតកម្មដំណាំស្រូវ ៣)ការទុកដាក់ រួមបញ្ចូលមានឃ្លាំងស្តុក និងម៉ាស៊ីនសម្ងួត ៤) ការទទួលឥណទាន ៥)ទីផ្សារ និង ៦)ការត្រៀមខ្លួនរបស់កម្ពុជា។

បន្ទាប់ពីការថ្លែងអំណរគុណដល់គ្រប់ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យរដ្ឋ ឯកជន និងដៃគូរអភិវឌ្ឍន៍នានា ចំពោះការសហការណ៍គាំទ្រការរៀបចំ

*(ត ទៅទំព័រទី ៥)*

(ត មកពីទំព័រទី ៨)


ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធាន CRF


ឯកឧត្តម **តុប សុភ័ក** អនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍


ឯកញ៉ា **តែ តាំខប៉** ប្រធាន FASMEC

នៅវេទិការនេះទ្បើង **ឯកឧត្តម សុខ ពុទ្ធិវុធ**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ( ស. អ. ក) បានកំណត់នូវរបៀបវារៈអាទិភាពចំនួន៣ សំខាន់ៗ ដែលសហព័ន្ធស្រូវអង្ករកម្ពុជាប្រកាន់ខ្ជាប់ក្នុងការអនុវត្តក្នុងរយៈពេលបីឆ្នាំខាងមុខនេះ។អាទិភាពទាំង៣ នោះរួមមាន៖ ពូជ ឃ្លាំងស្តុក និងម៉ាស៊ីនសម្ងួត និងចុងក្រោយគឺការទទួលឥណទាន និងការលក់ចេញទៅកាន់ទីផ្សារ។

ដៃគូររៀបចំព្រឹត្តិការណ៍វេទិកាស្រូវអង្ករលើកទី៥ **លោកឧកញ៉ា តែ តាំខប៉** ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជាបានចាត់ទុកកិច្ចសហការយ៉ាងជិតស្និទ្ធរវាងសហព័ន្ធស្រូវអង្ករកម្ពុជា និង សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជាគឺជាចំណុចសំខាន់ ក្នុងការនាំមកនូវព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏ល្អនេះ ដែលអាចនាំអ្នកពាក់ព័ន្ធទាំងអស់ មកចូលរួមក្នុងព្រឹត្តិការណ៍តែមួយ។

**លោកឧកញ៉ា តែ តាំខប៉** ក៏បានចាត់ទុកការនាំចេញអង្កររបស់កម្ពុជាទទួលបានជោគជ័យមួយកម្រិត ដោយនៅឆ្នាំ ២០១០ កម្ពុជាបាននាំចេញចំនួនតែ១០ ម៉ឺនតោន ហើយរហូតដល់ឆ្នាំ ២០១៥ ការនាំចេញបានកើនឡើងរហូតដល់ ៥៣ម៉ឺនតោន។

វេទិកាថ្នាក់ជាតិប្រចាំឆ្នាំនេះ ក៏បាននាំមកនូវកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិស្តីពីការជ្រើសស្រូវ- អង្ករល្អជាងគេ ដោយមានការចូលរួមត្រួតពិនិត្យដោយសហគណៈកម្មាការពីររូប គឺ **លោកឧកញ៉ា គីម សាវុធ** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងជាប្រធានក្រុមហ៊ុន ខ្មែរហ្វ៊ូត និង**លោកឧកញ៉ា ហ៊ុន ឡាក់** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងជាប្រធានក្រុមហ៊ុនមេគង្គ អូរីហ្សា។

លទ្ធផលនៃការប្រកួតប្រជែងដ៏តឹងតែង ដោយទទួលបានពីការសម្រឹតសម្រាំង និងការដាក់ពិន្ទុយ៉ាងហ្មត់ចត់ពីគណៈកម្មការបានបង្ហាញថា ក្រុមហ៊ុននិងសហគមន៍កសិកម្ម ចំនួន៥បានទទួលជ័យលាភីពីការប្រកួតប្រជែងនេះ។

១. ពានរង្វាន់ស្រូវល្អបំផុតផ្ការំដួលរបស់កម្ពុជា បានទៅលើ សហគមន៍សង្ហារផល
២. ពានរង្វាន់អង្ករសគ្រាប់វែងរបស់កម្ពុជា បានទៅលើ ក្រុមហ៊ុន អេមរ៉ុរ៉ាយ (Amru Rice)
៣. ពានរង្វាន់អង្ករចំហុយរបស់កម្ពុជា បានទៅលើ ក្រុមហ៊ុន ស៊ីកនេតឈ័រ អហ្វ អេស៊ា(Signature of Asia)
៤. ពានរង្វាន់អង្ករក្រអូបធម្មតារបស់កម្ពុជា បានទៅលើ ហុងហៀប គ្រុប (Hang Hiep Group)
៥. ពានរង្វាន់អង្ករក្រអូបល្អបំផុតរបស់កម្ពុជា បានទៅលើ ក្រុមហ៊ុនស៊ីធីរ៉ាយ (City Rice Import Export Co.,Ltd)

ក្រៅពីកម្មវិធីខាងលើនេះ សហព័ន្ធស្រូវអង្ករកម្ពុជាក៏បានរៀបចំឲ្យមានបទបង្ហាញពីអ្នកជំនាញក្នុងវិស័យកសិកម្មស្រូវអង្ករនេះ និង បុគ្គលិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលកំពុងកាន់គម្រោងអភិវឌ្ឍន៍សម្រាប់វិស័យស្រូវអង្ករនៅកម្ពុជា។

ក្នុងឱកាសបិទកម្មវិធីដោយមានវត្តមានរបស់ **ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល** ដែលកាលនោះជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានបង្ហាញពីការខិតខំរបស់ក្រសួងពាណិជ្ជកម្មក្នុងការលើកស្ទួយនិងជួយវិស័យស្រូវអង្ករកម្ពុជាតាមរយៈ ព្រឹត្តិការណ៍មួយចំនួនដែលក្រសួងបានរៀបចំនិងចូលរួមសកម្មភាព ដូចជា

- ការផ្គូរផ្គងពាណិជ្ជកម្ម
- ការតាំងពិព័រណ៌ទាំងក្នុង និងក្រៅប្រទេសដើម្បីស្វែងពង្រីកទីផ្សារអង្ករកម្ពុជា
- ការកាត់បន្ថយនូវនីតិវិធីមួយចំនួនទាក់ទងនិងការនាំចេញស្រូវអង្ករ
- ការបង្កើតច្រកចេញចូលតែមួយ សំរាប់ផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញ និងលិខិតបទដ្ឋានផ្សេងៗ
- ការដាក់អោយស្នើរសុំវិញ្ញាបនបត្រប្រភពដើមទំនិញ CO តាមប្រព័ន្ធអនទ្បាញ

បើទោះបីមានការខិតខំប្រឹងប្រែងជារួមបែបនេះក្តី តែវិស័យស្រូវអង្ករនៅតែប្រឈមបញ្ហាជាច្រើនទៀត ដែលទាមទារឲ្យមានការចូលរួមនិងផ្តោតការយកចិត្តទុកដាក់ទាំងអស់គ្នា។ នៅក្នុងសុន្ទរកថារបស់ **សម្តេចតេជោ ហ៊ុន សែន** ក្រសួងបី និងស្ថាប័នឯកជនមួយដែល សម្តេចតេជោ បានកោតសរសើរក្នុងការងារបង្កើនផលិតកម្មស្រូវ និងជំរុញការនាំចេញ។ ក្រសួងនិងស្ថាប័នឯកជនទាំងបួននោះគឺ

1. ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ដែលជាផ្នែកផលិតកម្មស្រូវ
2. ក្រសួងពាណិជ្ជកម្ម ដែលជាផ្នែកនាំចេញអង្ករទៅកាន់ទី-ផ្សារអន្តរជាតិ
3. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាផ្នែកផ្តល់ហិរញ្ញប្បទាន
4. សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការជំរុញការទទួលស្គាល់ជាអន្តរជាតិ។

**សម្តេចតេជោ ហ៊ុន សែន** ក៏បានថ្លែងការអរគុណដល់កសិករដែលបានខិតខំប្រឹងប្រែងតស៊ូ ព្យាយាម និងសង្វាត ក្នុងការងារបង្កបង្កើនផលស្រូវ ហើយផលិតបានអង្ករដ៏ឆ្ងាញសម្រាប់ពិភពលោក៕

## កិច្ចប្រជុំចែករំលែកបទពិសោធន៍ និងព័ត៌មានរវាងអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករនៅខេត្តសៀមរាប និងសហព័ន្ធស្រូវអង្ករកម្ពុជា

នៅព្រឹកទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៦ នៅវិទ្យាល័យពួក ស្ថិតក្នុងស្រុកពួក ខេត្តសៀមរាបមានរៀបចំកិច្ចប្រជុំមួយជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករក្នុងខេត្តសៀមរាប។ អ្នកចូលរួមសរុបប្រមាណ ២៤០នាក់ តំណាងមកពី មន្ទីរ និងការិយាល័យកសិកម្ម អភិបាលស្រុក បុគ្គលិក GIZ បុគ្គលិក សហព័ន្ធស្រូវអង្ករ និងតំណាងកសិករមកពី ១១ស្រុក ខេត្តសៀមរាប។

គោលបំណងសំខាន់នៃកិច្ចប្រជុំរួមមាន៖ (១) ចែករំលែកបទពិសោធន៍ក្នុងការលើកកម្ពស់វិស័យស្រូវអង្ករ របស់អ្នកពាក់ព័ន្ធក្នុងខេត្តសៀមរាប (២) ផែនការរបស់សហព័ន្ធស្រូវអង្ករកម្ពុជា នឹងទីផ្សារស្រូវអង្ករបច្ចុប្បន្ន (៣) ពិភាក្សាពីលទ្ធភាពបង្កើនកិច្ចសហការល្អរវាងកសិករអ្នកផលិត និងអ្នកទិញនៅក្នុងខេត្តសៀមរាប ដើម្បីឆ្លើយតបស្តង់ដារគុណភាព និងបរិមាណសម្រាប់នាំចេញ។

នៅក្នុងអំឡុងពេលកិច្ចប្រជុំ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានស្វាគមន៍ និងណែនាំជាសង្ខេបអំពីសហព័ន្ធជូនដល់ក្រុមកសិករ។ លើសពីនេះ លោក ផង់ ផល្លា បានធ្វើបទបង្ហាញអំពីផែនការផ្នែកផលិតកម្មនិងពូជ របស់សហព័ន្ធជូនដល់អង្គប្រជុំនិងក្រុមកសិករ។

ជាលទ្ធផល តំណាងកសិករទាំង ១១ស្រុកដែលបានចូលរួម បានសម្តែងការរីករាយ និងសប្បាយចិត្តបន្ទាប់ពីបានស្គាល់និងដឹងអំពីផែនការរបស់សហព័ន្ធក្នុងការជួយដល់ក្រុមកសិករជាអ្នកផលិត។ ក្រុមកសិករក៏បានសំណូមពរឲ្យ សហព័ន្ធជួយធ្វើយ៉ាងណារកទីផ្សារលក់ស្រូវ របស់គាត់ក្នុងតម្លៃមួយសមរម្យ និងអាចចំណេញបាន៕





*រូបភាពនៅវិទ្យាល័យពួក ស្ថិតក្នុងស្រុកពួក ខេត្តសៀមរាប*

## កិច្ចប្រជុំពិភាក្សាការងារស្តីពីកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការ GIZ

នៅរសៀលថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងាររបស់សហព័ន្ធស្រូវអង្ករកម្ពុជាដឹកនាំ ដោយប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានជួបប្រជុំពិភាក្សាការងារស្តីពីកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការ GIZ នៅការិយាល័យអង្គការ GIZ ប្រចាំខេត្តសៀមរាប។

គោលបំណងសំខាន់នៃកិច្ចប្រជុំ គឺដើម្បីជជែកអំពីកិច្ចសហការគ្នារវាងសហព័ន្ធស្រូវអង្ករកម្ពុជា ជាមួយអង្គការ GIZ ជាពិសេសកម្មវិធីអភិវឌ្ឍន៍តំបន់ ប្រចាំខេត្តសៀមរាប ខណៈដែលកម្មវិធីនេះបាន និងកំពុងទទួលបានជោគជ័យ និងបានពង្រីកការងាររបស់ខ្លួនទៅកាន់ខេត្តចំនួនពីរបន្ថែមទៀតគឺ ខេត្តបន្ទាយមានជ័យ នឹងឧត្តរមានជ័យ៕



*រូបភាពនៅការិយាល័យអង្គការ GIZ ខេត្តសៀមរាប*

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធស្រូវអង្ករកម្ពុជាលើកទី១១

នៅរសៀលថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៦ វេលាម៉ោង ១៤.០០ ដល់ ១៨.០០នាទី លោក **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ១១ នៅការិយាល័យសហព័ន្ធស្រូវអង្ករកម្ពុជា ដែលមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន១៣រូប ទីប្រឹក្សា និងលេខាធិការដ្ឋាន ដើម្បីពិភាក្សាលើប្រធានបទសំខាន់គឺ " **ការពិភាក្សា និង ផ្តល់មតិយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេល៥ឆ្នាំ របស់សហព័ន្ធ**"។

ក្រោយពីមានការពិភាក្សាផ្លាស់ប្តូរមតិយោបល់រួចមក ក្រុមប្រឹក្សាភិបាលមានមតិឯកភាពគ្នាពីផែនការ ដែលបានលើកជាដំណោះស្រាយលើបញ្ហាប្រឈមសម្រាប់វិស័យស្រូវអង្ករកម្ពុជា ដែលជាដំណាក់កាល ដូចតទៅ៖

**ក. បញ្ហាប្រឈមជាអាទិភាព** (**ត្រូវដោះស្រាយក្នុងរយៈខ្លី និងបន្ទាន់**)៖

**១**/. បញ្ហាការនាំអង្ករចូលមកពីប្រទេសជិតខាង ដែលបាននិងកំពុងធ្វើឲ្យប៉ះពាល់ដល់រោងម៉ាស៊ីនក្នុងស្រុក ដែលអាចនឹងឈានទៅរកការបិទទ្វារមួយចំនួនពេលខាងមុខ ដោយមូលហេតុថ្លៃដើមក្នុងការផលិតអង្ករប្រទេសជិតខាងទាបជាងអង្ករកម្ពុជា ធ្វើឲ្យរោងម៉ាស៊ីនក្នុងស្រុកមិនអាចប្រកួតប្រជែងបាន។

*(ត ទៅទំព័រទី ៧)*

(ត មកពីទំព័រទី ៦)



ជាដំណោះស្រាយ៖ ដោយសមាជិកក្រុមប្រឹក្សាភិបាល បានលើកឡើងជាដំណោះស្រាយ ដែលគ្រោងនឹងស្នើសុំទៅរដ្ឋាភិបាលដើម្បីអន្តរាគមន៍លើបញ្ហានេះថា ដោយអ្នកនាំចូលអង្ករទាំងអស់ គួរតែមានអាជ្ញាប័ណ្ណនាំចូល (Import License) ដើម្បីត្រួតពិនិត្យ គុណភាព និងអនាម័យជាដើម។

**ខ. បញ្ហាប្រឈមជាអាទិភាព (ត្រូវដោះស្រាយក្នុងរយៈមធ្យម)៖**

**២**/. បញ្ហាកង្វះទុនបង្វិលសម្រាប់ទិញស្រូវនៅរដូវប្រមូលផល និងកម្ចីដែលមានអត្រាការប្រាក់ទាប ដែលត្រូវផ្តល់ឥឲ្យទាន់ពេលវេលា។

**៣** /. បញ្ហាតម្លៃអគ្គិសនីសម្រាប់រោងម៉ាស៊ីនកិន កែច្នៃខ្ពស់ពេក (ប្រមាណ ២៥% នៃថ្លៃដើម)។

**ជាដំណោះស្រាយ៖** ដោយសមាជិកក្រុមប្រឹក្សាភិបាល បានលើកឡើងដោះស្រាយតាមរយៈគណៈកម្មាធិការទាំង៥ របស់សហព័ន្ធ ឬបង្កើតគណៈកម្មការបន្ថែម និងតាមរយៈក្រុមការងារទី៩ (ក្រុមការងារស្រូវអង្ករ នៃវេទិការវាងរាជរដ្ឋាភិបាល និងវិស័យឯកជន) ដែលនឹងត្រូវសិក្សាបន្ថែម និងពិនិត្យពីលទ្ធភាពដើម្បីស្នើសុំទៅរដ្ឋាភិបាលក្នុងការជួយអន្តរាគមន៍ ដូចជា កម្ចីដែលមានអត្រាការប្រាក់ទាបប្រមាណ ៤% និងតំលៃអគ្គិសនីនៅត្រឹមតែចន្លោះពី ៤០០-៥០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង សម្រាប់រោងម៉ាស៊ីនកិនកែច្នៃ។

**គ.បញ្ហាផ្សេងៗ រួមមាន៖**

**៤**/. បញ្ហាកង្វះនូវឃ្លាំងស្តុក និងម៉ាស៊ីនសម្ងួតសម្រាប់ប្រមូលស្រូវស្តុកទុកនូវរដូវប្រមូលផល

**៥**/. បញ្ហាកង្វះពូជសុទ្ធ និងប្រើប្រាស់ពូជមិនចំតម្រូវការទីផ្សារ

**៦**/. បញ្ហាថ្លៃដើមនៃការដឹកជញ្ជូនខ្ពស់ធៀបទៅនឹងប្រទេសជិតខាង

**៧**/. កង្វះឃ្លាំងស្តុកនៅកំពង់ផែ និងការចរចារស្វែងរកលទ្ធភាពប្រើប្រាស់នៅកំពង់ផែរបស់ប្រទេសជិតខាង ដើម្បីកាត់បន្ថយថ្លៃដើមការដឹកជញ្ជូនសម្រាប់ខេត្តមួយចំនួនដែលនៅជិតព្រំដែន ជាដើម។

**ជាដំណោះស្រាយ៖** បញ្ហាទាំងនេះត្រូវបានបញ្ចូលទៅក្នុងផែនការរបស់សហព័ន្ធ ដើម្បីដោះស្រាយជាជំហានៗ តាមរយៈគណៈកម្មាធិការទាំង ៥ របស់សហព័ន្ធ ឬបង្កើតគណៈកម្មការបន្ថែម និងក្រុមការងារទី៩ ដែលជាក្រុមការងាររវាងរដ្ឋ និងឯកជន ដោយផ្តោតលើវិស័យស្រូវអង្ករកម្ពុជាទាំងមូល។

**សំគាល់៖** សហព័ន្ធ នឹងរៀបចំឲ្យមានកិច្ចប្រជុំជាមួយសមាជិក និងភាគីពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករ ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់នាពេលឆាប់ៗនេះ។ កិច្ចប្រជុំត្រូវបានបញ្ចប់ដោយទទួលបានផ្លែផ្កា និងលទ្ធផលល្អ ប្រកបដោយភាពស្និទ្ធស្នាល៕







រូបភាពកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ១១ នៅការិយាសហព័ន្ធស្រូវអង្ករកម្ពុជា





# កិច្ចប្រជុំពិភាក្សានិងពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវ អង្ករ របស់សហព័ន្ធស្រូវអង្ករកម្ពុជា

នៅព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានដឹកនាំកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយសមាជិក អ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ប្រមាណជាជាង ១០០នាក់ ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ។

របៀបវារៈសំខាន់ៗរួមមាន៖
(១). កិច្ចប្រជុំពិភាក្សា ស្ដីពី បង្កើតគណៈកម្មការដោះស្រាយបញ្ហាប្រឈមបន្ទាន់សម្រាប់វិស័យស្រូវអង្ករកម្ពុជា។
(២). សន្និសីទសារព័ត៌មាន ស្ដីពី យន្តការដោះស្រាយបញ្ហាប្រឈមបន្ទាន់សម្រាប់វិស័យស្រូវអង្ករកម្ពុជា។
(៣). កិច្ចប្រជុំពិភាក្សា ស្ដីពី ការបង្កើតជាសម្ព័ន្ធដៃគូក្រុមហ៊ុន និងអ្នកវិនិយោគិន ការបង្កើតម៉ាករួមអង្ករកម្ពុជា និងផែនការធ្វើពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិដឹកនាំដោយសហព័ន្ធស្រូវអង្ករកម្ពុជា។

ជាលទ្ធផល អង្គប្រជុំមានការគាំទ្រដោយសម្លេង ១០០% សម្រេចបានដូចខាងក្រោម៖
(១). សម្រេចបង្កើតគណៈកម្មការដោះស្រាយបញ្ហាប្រឈមបន្ទាន់មួយ ដើម្បីរកយន្តការជួយដល់វិស័យស្រូវអង្ករ លើចំណុចសំខាន់ៗបន្ទាន់ពីរ៖
ក/. ការដោះស្រាយបញ្ហាការនាំចូលអង្ករដែលមិនបានបង់ពន្ធតាមច្បាប់ ដែលធ្វើឲ្យប៉ះពាល់ដល់វិស័យស្រូវអង្ករកម្ពុជាទាំងមូល ជាពិសេសរោងម៉ាស៊ីនកិនស្រូវនាពេលបច្ចុប្បន្ននេះ។
ខ/. ការរៀបចំចងក្រងនូវឯកសារពាក់ព័ន្ធ ដើម្បីដាក់សំណើស្នើសុំទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពិនិត្យរកលទ្ធភាពផ្ដល់នូវកញ្ចប់ឥណទានបន្ទាន់មួយចំនួន តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីជួយកាត់បន្ថយនូវបញ្ហាប្រឈម សម្រាប់ជួយដល់រោងម៉ាស៊ីនកិនស្រូវ។
(២). ការធ្វើសន្និសីទសារព័ត៌មាន ស្ដីពី យន្តការដោះស្រាយបញ្ហាប្រឈមបន្ទាន់សម្រាប់វិស័យស្រូវអង្ករកម្ពុជា។
(៣). -បង្កើតការចងជា ″ សម្ព័ន្ធដៃគូរបស់សមាជិកសហព័ន្ធនិងអ្នកវិនិយោគធំៗ (Consortium Partners)″ ដើម្បីមានលទ្ធភាពក្នុងប្រមូលផ្ដុំនូវប្រភពទុន និងបង្កើតការជឿជាក់ពីសំណាក់អ្នកផ្ដល់កម្ចី និងឈ្មួញទិញ អង្ករធំៗ ដែលអាចនឹងធ្វើឲ្យមាននិរន្តភាពសម្រាប់ការផ្គត់ផ្គង់អង្ករកម្ពុជានាពេលអនាគត។
- សមាជិកសហព័ន្ធ អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា បានគាំទ្រលើការបង្កើតម៉ាករួមអង្ករកម្ពុជា ដែលនឹងត្រូវដាក់ស្នើសុំការចុះបញ្ជីពីក្រសួងពាណិជ្ជកម្មកម្ពុជា និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងពេលឆាប់ៗខាងមុខ។
- សម្រេចលើផែនការការធ្វើពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ដែលដឹកនាំដោយសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះនិងម៉ាកអង្ករកម្ពុជា ព្រមទាំងស្វែងទីផ្សារបន្ថែម។

កិច្ចប្រជុំត្រូវបានបញ្ចប់ ទទួលបាននូវលទ្ធផលផ្លែផ្កា និងការគាំទ្រយ៉ាងផុសផុលពីសមាជិក អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា នៅវេលាម៉ោង ១៧.៣០នាទីល្ងាច៕



រូបភាពនៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ

## ជំនួបប្រជុំរវាងអគ្គនាយកដ្ឋានពន្ធដារ និងសហព័ន្ធស្រូវអង្ករកម្ពុជា ( ស.អ.ក )

ក្នុងជំនួបប្រជុំជាលើកទី៣ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ជាមួយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលដឹកនាំដោយ ឯកឧត្តម **វ៉ាន់ ពុទ្ធិពល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និងលោកឧកញ៉ា **គឹម សាវុធ** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិង ជាប្រធានគណៈកម្មាធិការប្រកួតប្រជែងថ្លៃដើម និងសមាជិក ព្រមទាំងលេខាធិការដ្ឋាន ស. អ. ក ដើម្បីពិភាក្សា ស្តីពី "ការស្នើសុំលើកលែងអាករលើតំលៃបន្ថែម (VAT១០%) សម្រាប់ផលិតផលអង្ករ" នៅព្រឹកថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជាលទ្ធផលៈ យើងទទួលបានលទ្ធផលជាវិជ្ជមាន ដោយ ឯកឧត្តម បានមានប្រសាសន៍ថា ទំហំនៃ VAT១០% ដែលប្រមូលបានមកពីផលិតផលអង្ករនេះ បើប្រៀបធៀបនឹងV A T ពីផលិតផលផ្សេងៗទៀត គឺប្រមាណ០.១%តែប៉ុណ្ណោះ ដែលមានទំហំតិចតួចណាស់ ដូច្នេះដើម្បីជាការលើកលើកទឹកចិត្តដល់ប្រជាកសិករ អ្នកផលិត និងជាពិសេសសម្រាប់រោងម៉ាស៊ីន គួរតែលើកលែងជូន ដោយខាងអគ្គនាយកដ្ឋានពន្ធដារបានប្រមូលចងក្រងឯកសារ និងនឹងរៀបចំសំណើដាក់ជូនរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្លូវច្បាប់ និងសម្រេចជាផ្លូវការ។ លើសពីនេះទៅទៀត ឯកឧត្តម បានបង្ហើបទៀតដែរថា ចំពោះការស្នើសុំលើកលែង VAT នេះ គឺមិនត្រឹមតែផលិតផលអង្ករមួយមុខទេ គឺអាចនឹងមានផលិតផលដទៃទៀត ដូចជា ដំឡូងមី ពោត ជាដើម។



*រូបភាពនៅសាលប្រជុំអគ្គនាយកដ្ឋានពន្ធដារ*



## កិច្ចប្រជុំលើកទី ៦ របស់គណៈកម្មាធិការប្រតិបត្តិផ្នែកផលិតកម្មស្រូវ និងការកែច្នៃ ( FMP-Exco )

នៅរសៀលថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ក្រោមអធិបតីភាពប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានចូលរួមបើកកិច្ចប្រជុំលើកទី៦ របស់គណៈកម្មាធិការប្រតិបត្តិផ្នែកផលិតកម្មស្រូវ និងការកែច្នៃ ដែលដឹកនាំដោយ ឧកញ៉ា **វង្ស ម៉ិនហេង** នៅការិយាល័យសហព័ន្ធស្រូវអង្ករកម្ពុជា ដោយមានការចូលរួមពីសមាជិកគណៈកម្មាធិការ ដៃគូអភិវឌ្ឍន៍នានា ដូចជា ខាង AFD និង SNEC ជាដើម សរុបប្រមាណជា ២៥នាក់។

របៀបវារៈនៃកិច្ចប្រជុំរួមមាន ៣ ចំនុចសំខាន់ៗ៖ (១) ពិនិត្យលើសមាសភាពនៃសមាជិកគណៈកម្មាធិការផលិតកម្ម និងការកែច្នៃ និងការស្នើសុំដាក់បញ្ចូលសមាជិកថ្មីបន្ថែម។ (២) ពិភាក្សាផ្លាស់ប្តូរមតិយោបល់លើប្រព័ន្ធទិញលក់ស្រូវរួមគ្នា និងគំរូនៃការធ្វើកសិកម្មតាមកិច្ចសន្យា(Contract Farming)។ (៣) ពិនិត្យនិងសម្រេចអំពីយន្តការលើប្រភេទពូជសែនក្រអូប។

ជាលទ្ធផលនៃកិច្ចប្រជុំសម្រេចបានដូចតទៅ៖

(**១**) បានឯកភាពទទួលយកសមាសភាពសមាជិកថ្មីជំនួសសមាជិកចាស់ ២រូប និងបន្ថែមសមាជិកថ្មី ២រូបទៀត ដែលជាតំណាងសហព័ន្ធកសិករ។ ដូច្នេះបច្ចុប្បន្នសមាជិកនៃគណៈកម្មាធិការនេះសរុបមាន ១៧រូប។

(**២**) បន្ទាប់ពីបានស្តាប់បទបង្ហាញ និងពិភាក្សាគ្នារួច អង្គប្រជុំឯកភាពសហការណ៍គ្នារវាង SNEC និង FMP-Exco ក្នុងការជជែកពីលទ្ធភាពការជួយគាំទ្ររបស់ SNEC ដល់គណៈកម្មាធិការនេះ។ គណៈកម្មាធិការបានឯកភាពសហការគាំទ្រពី SNEC ទៅលើ ការសិក្សាកិច្ចសន្យាកសិកម្ម និង ប្រព័ន្ធលក់ទិញស្រូវរួមគ្នា (Paddy Collective Plan Form) ហើយគ្រោងពិភាក្សា និងសិក្សាបន្ថែមអំពី គំរូកិច្ចសន្យាកសិកម្ម ថាតើអាចយកគំរូណាមួយសម្រាប់មកអនុវត្តជួយដល់វិស័យស្រូវ ដើម្បីឲ្យដំណើរការបានល្អទាំងកសិករ និងម្ចាស់រោងម៉ាស៊ីនស្រូវ ដើម្បីដាក់បង្ហាញក្នុងសិក្ខាសាលាមួយនៅក្នុងខែ ៤។

(**៣**) អង្គប្រជុំឯកភាព **៣** ចំនុចអំពី យន្តការលើប្រភេទពូជសែនក្រអូបដូចខាងក្រោម៖

ទី១៖ ជម្រុញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះបញ្ជីពូជស្រូវសែនក្រអូបជាពូជជាតិ និងជម្រុញការផលិត។

ទី២៖ នឹងរៀបចំកិច្ចប្រជុំបច្ចេកទេសរវាងភាគីពាក់ព័ន្ធ។

ទី៣៖ បានឯកភាពជ្រើសរើសតំណាងចេញពីគណៈកម្មាធិការចំនួន ៦រូប ដើម្បីជជែកជាមួយភាគីពាក់ព័ន្ធ៕



# ដំណើរទស្សនកិច្ចទៅកាន់មូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ ដែលជាសមាជិកថ្មីរបស់សហព័ន្ធ



នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ នេះ សហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយលោក **សុខ ពុទ្ធិវុធ** និងសមាជិកក្រុមប្រឹក្សាភិបាល ព្រមទាំងលេខាធិការដ្ឋាន បានធ្វើចុះទស្សនកិច្ច និងសំណេះសំណាល ជាមួយនៅមូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ ដែលមានផ្ទៃដីដាំដុះជាង ១,៦៩០ហិចតា នៅឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល។

លោកប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានកោតសរសើរចំពោះគំនិតផ្តួចផ្តើមអភិវឌ្ឍន៍វិស័យកសិកកម្ម ជាពិសេសដំណាំស្រូវក្រអូបនៅក្នុងរដូវប្រាំង ដោយមានប្រព័ន្ធគ្រប់គ្រងទឹកច្បាស់លាស់ ដើម្បីទទួលបានទិន្នផលខ្ពស់ថែមទៀត។

តំណាងក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ បានបញ្ជាក់ថា ទោះបីទើបតែជាសមាជិកថ្មីរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ប៉ុន្តែក្រុមហ៊ុននឹងសហការគាំទ្រយ៉ាងជិតស្និទ្ធ ដើម្បីខិតខំលើកស្ទួយវិស័យស្រូវអង្ករ ក៏ដូចជាជួយដល់សេដ្ឋកិច្ចកម្ពុជា។

លោកបានបន្ថែមទៀតថា នេះជាគម្រោងទី១ ដោយក្រុមហ៊ុននឹងមានគម្រោងទី២ ទៀត ដែលមានផ្ទៃដីជាង ១០,០០០ហិចតា។

លោកប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានសង្កត់ធ្ងន់ថា ការដែលយើងអាចទាញយកនូវបច្ចេកវិទ្យាគ្រឿងចក្រកសិកម្ម មកប្រើប្រាស់ គឺនឹងជួយបង្កើនប្រសិទ្ធភាពការផលិត និងទិន្នផលបានខ្ពស់ ដែលវាជាផ្នែកមួយក្នុងការកាត់បន្ថយថ្លៃដើមក្នុងការប្រកួតប្រជែង។ ទោះជាយ៉ាងណាប្រទេសយើងមានផ្ទៃដី និងទីតាំងភូមិសាស្ត្រអំណោយផលស្រាប់ នោះយើងត្រូវធ្វើយ៉ាងណាដើម្បីប្រើប្រាស់ផ្ទៃដីដាំដុំរបស់យើងឲ្យមានជីជាតិបានយូរអង្វែង៕









រូបភាពនៅមូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍









# លទ្ធផលសង្ខេប នៃកិច្ចប្រជុំក្រុមការងារទី៩ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កិច្ចប្រជុំនៃវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ក្រុមការងារស្រូវអង្ករ



*រូបភាពកិច្ចប្រជុំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

កិច្ចប្រជុំត្រូវបានប្រព្រឹត្តទៅក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជនដោយមានការចូលរួមពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុប្រធានប្រចាំការ **ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានក្រុមការងារទី៩ សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា និងមន្ត្រីអញ្ជើញមកពីស្ថាប័នពាក់ព័ន្ធនានា។



កិច្ចប្រជុំបានផ្តោតលើបញ្ហាប្រឈមនានា ក្នុងវិស័យស្រូវអង្ករដែលបានលើកដោយសហព័ន្ធស្រូវអង្ករកម្ពុជា និងបានធ្វើការសម្រេចជាលទ្ធផលមួយចំនួនដូចតទៅ៖

**១** - បង្ការការហូរចូលអង្ករដែលមិនបង់ពន្ធតាមច្បាប់

- រាជរដ្ឋាភិបាល នឹងពង្រឹងការយកពន្ធគយនៅតាមព្រំដែន។ ហើយវិធានការទប់ស្កាត់តាមរយៈការដាក់កូតា ឬអជ្ញាប័ណ្ណឬភូតគាមអនាម័យគឺមិនអាចធ្វើទៅរួច ព្រោះផ្ទុយពីកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងៗ ដូចជាអាស៊ាន និង WTO ជាដើម។

-រាជរដ្ឋាភិបាលនឹងសិក្សាលើការកែសម្រួលនូវតម្លៃយោងសំរាប់ការបង់ពន្ធគយ។

**២** - ទប់ស្កាត់ការលាយអង្ករណាមួយ ដែលនាំអោយមានការប្រកួតប្រជែងមិនស្មើភាព

-ក្រសួងពាណិជ្ជកម្មចាត់វិធានការតាមដានអោយបានម៉ត់ចត់។ បើរកឃើញថាក្រុមហ៊ុនណាមួយមានលាយអង្ករបរទេស និងបញ្ឈប់ការផ្តល់COនាំចេញ។

**៣**- VAT សម្រាប់ផលិតផលកសិកម្មលក់ក្នុងស្រុកនឹងត្រូវលើកលែងបន្ទាប់ពីអនុក្រឹត្យនឹងចេញក្នុងពេលឆាប់ៗ

**៤** - ការផ្តល់កំចីពីរាជរដ្ឋាភិបាលរដ្ឋាភិបាលអាចផ្តល់កំចីតាមរយៈ R D B បានលុះត្រាតែមានប្រព័ន្ធណាមួយដើម្បីធានាថាលុយដែលអោយខ្ចី មិនបាត់បង់។ សំរាប់អត្រាការប្រាក់ គឺមិនអាចតិចជាងធនាគារពាណិជ្ជខ្លាំងដែលនាំអោយប៉ះពាល់ទីផ្សារបានទេ។

**៥** - គម្រោងឃ្លាំងរដ្ឋាភិបាល បាននិងកំពុងសិក្សាគម្រោងនេះជាមួយដៃគូហើយក៏ស្វាគមន៍ការផ្តល់មតិចូលរួមពី សហព័ន្ធ។

**៦**- សម្រាប់លទ្ធភាពដឹកទំនិញតាមកំពង់ផែ ឡាមចាបាំងរាជរដ្ឋាភិបាលកំពុង ចរចារជាមួយភាគីថៃ។

**៧**- ការបញ្ចុះតម្លៃអគ្គិសនីរដ្ឋាភិបាលចុះពី ២៥សេន មក ១៦.៧៥សេន ក្នុងគីឡូវ៉ាត់ម៉ោង រួចហើយហើយមិនអាចចុះបន្ថែមទៀត តាមរយៈការឧបត្ថម្ភទុនបានទេ។

**៨**- បញ្ហាដឹកជញ្ជូនមានតម្លៃខ្ពស់ ទោះបីជាតម្លៃប្រេងឥន្ធនៈមានការធ្លាក់ចុះបញ្ហានេះនឹងលើកទៅពិភាក្សា ជាមួយក្រុមហ៊ុនដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធតាមរយៈក្រុមការងារ "ច" ៕





# អំពីគណៈកម្មការទទួលបន្ទុកដោះស្រាយបញ្ហាប្រឈមបន្ទាន់

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ៩៦/១៦ ស.អ.ក

**សហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រកាស**

**ស្តីពី**

ការបង្កើតគណៈកម្មការទទួលបន្ទុកដោះស្រាយបញ្ហាប្រឈមបន្ទាន់ សម្រាប់វិស័យស្រូវអង្ករកម្ពុជា
(Ad-Hoc Committee for Solving Short Term Challenges in Rice Sector)

**យោង៖** - អនុក្រឹត្យស្តីពីការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤
- លក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាទកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសហព័ន្ធជាមួយសមាជិកភាគីពាក់ព័ន្ធសំខាន់ៗ នៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១៦
- តាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

**សម្រេច**

**ប្រការ១.**

បង្កើតគណៈកម្មការទទួលបន្ទុកដោះស្រាយបញ្ហាប្រឈមបន្ទាន់សម្រាប់វិស័យស្រូវអង្ករកម្ពុជា ដែលមានសមាសភាពចំនួន១៣រូប និងលេខាធិការចំនួន០១រូប ដូចខាងក្រោម៖

| | |
|---|---|
| ១. ឧកញ៉ា ភូ ពុយ | ប្រធាន |
| ២. ឧកញ៉ា ប្រាយ សុន | អនុប្រធាន |
| ៣. លោកបណ្ឌិត សុខ ហាច | អនុប្រធាន |
| ៤. ឯកឧត្តម អ៊ិត វិជិត | អនុប្រធាន |
| ៥. ឧកញ៉ា ចាន់ សុឃាំង | សមាជិក |
| ៦. ឧកញ៉ា សុង សារ៉ែន | សមាជិក |
| ៧. ឧកញ៉ា វង្ស ប៊ុនហេង | សមាជិក |
| ៨. ឯកឧត្តម ដារ៉ាសិទ្ធី អ៊ុំ | សមាជិក |
| ៩. លោក ហ៊ាង វុត្ថា | សមាជិក |
| ១០. លោក នង វាសនា | សមាជិក |
| ១១. លោក កាន់ គន្ធី | សមាជិក |
| ១២. លោក ឡាយ ឈុនហួ | សមាជិក |
| ១៣. លោក រស់ សុជារិទ្ធ | សមាជិក |
| ១៤. លោក មូល សារិទ្ធី | លេខាធិការ |

**ប្រការ២.**

គណៈកម្មការមានភារៈកិច្ចអនុវត្តការងារលើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាលសហព័ន្ធនូវតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- 1-

#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

១. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំយន្តការដោះស្រាយបញ្ហាការនាំចូលអង្ករពីក្រៅប្រទេស និងបញ្ហាប្រឈមដទៃផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់វិស័យស្រូវអង្ករកម្ពុជាទាំងមូល។

២. រៀបចំចងក្រងនូវឯកសារពាក់ព័ន្ធ ដើម្បីដាក់សំណើស្នើសុំទៅកាន់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងៗដ៏ទៃទៀត ដើម្បីពិនិត្យលទ្ធភាពផ្តល់ឥណទានជួយដល់វិស័យស្រូវអង្ករកម្ពុជា ដែលកំពុងជួបប្រទះបញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះ។

៣. គណៈកម្មការ ត្រូវធ្វើរបាយការណ៍លទ្ធផលកិច្ចប្រជុំ ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ក្នុងករណីការងារណាដែលមិនមានចែងក្នុងក្របខណ្ឌខាងលើទេ គណៈកម្មការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាតសំរេចជាមុន។

៤. ក្នុងករណីចាំបាច់ គណៈកម្មការអាចស្នើសុំបន្ថែមសមាជិកនិងទីប្រឹក្សាបន្ថែមទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបានដោយត្រូវមានការចូលរួមពីសមាជិកហាសិបបូកមួយ (៥០+១)នៃសមាសភាពសរុប និងអាចអនុម័តបាន លុះត្រាមានសំលេងគាំទ្រហាសិបបូកមួយ (៥០+១) នៃសមាសភាពដែលបានចូលរួមប្រជុំ។

**ប្រការ៤.**

គណៈកម្មការនេះ មានសុពលភាពត្រឹមពេលបញ្ចប់ភារកិច្ចដោះស្រាយបញ្ហាប្រឈម ដូចមានចែងក្នុងប្រការ២ខាងលើ។

**ប្រការ៥.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

ស.អ.ក CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

**<u>ចម្លងជូន៖</u>**

- ខុទ្ទកាល័យ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណៈការនិងដឹកជញ្ជូន
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដៃគូអភិវឌ្ឍន៍ IFC, AFD
- ដូចប្រការ ៣&៤
- ឯកសារ កាលប្បវត្តិ

- 2-


(ត ទៅទំព័រទី ១៦)

# អំពីការងារស្រាវជ្រាវ និងគូសទីតាំងសមាជិកសហព័ន្ធ

**ការបណ្តុះបណ្តាលកម្មវិធី** Sirrus

កម្មវិធី Sirrus គឺជាកម្មវិធីមួយដែលប្រើក្នុងវិស័យកសិកម្ម។ គេអាចប្រើប្រាស់កម្មវិធីនេះជាមួយឧបករណ៍ iPAD ដែលអាចបម្រើនូវមុខងារមួយចំនួនដូចខាងក្រោម៖

(១) វាស់ដីដោយប្រើប្រាស់ GPS

(២) គូសក្បាលដីដោយប្រើប្រាស់រូបថតផ្កាយរណប

(៣) ប្រមូលព័ត៌មានអំពីបញ្ហារបស់រុក្ខជាតិមាន (សត្វល្អិតបំផ្លាញ, ជំងឺផ្សេងៗ, កម្រិតpH របស់ដី,...) និងព័ត៌មានអំពីសហគមន៍កសិកម្មនីមួយៗ (ឈ្មោះកសិករ, ចំនួនប្រាក់កម្ចី, ប្រភេទពូជ, របៀបដាំដុះ,...)

(៤) បង្ហាញព័ត៌មានអំពីអាកាសធាតុ ដែលទទួលបានពីរ៉ាដារបស់ប្រទេស អូស្ត្រាលី និងសហរដ្ឋអាមេរិច រួមជាមួយផ្កាយរណបផងដែរ។

(៥) ចែករំលែកទិន្នន័យទៅឲ្យអ្នកប្រើប្រាស់ដទៃទៀត និងបង្ហាញជារបាយការណ៍។

កម្មវិធីនេះ អាចជួយសម្រួលដល់ការកត់ត្រាអំពីដំណើរការលូតលាស់នៃដំណាំកាន់តែជាក់លាក់ និងមានប្រសិទ្ធភាព។

សហព័ន្ធក៏បានបើកវគ្គបណ្តុះបណ្តាលសាកល្បងនៃការប្រើប្រាស់កម្មវិធីនេះ ទៅដល់និស្សិតនិងមន្ត្រីកសិកម្មប្រមាណជា១០នាក់ នៅខែកុម្ភៈនិងមីនា។ ជាមួយនឹងកម្មវិធីនេះ អាចអោយគេងាយស្រួលដល់ការដាំដុះ ការគ្រប់គ្រងទិន្នន័យការដាំដុះកាន់តែមានប្រសិទ្ធភាព និងជាក់លាក់។

សំរាប់ព័ត៌មានពិស្តារសូមចូលទៅកាន់ www.sstsoftware.com















**គិតត្រឹមខែមីនា ឆ្នាំ២០១៦នេះ យើងបានធ្វើនូវការងារមួយចំនួនរួមមាន៖**

• កសាងផែនទីដូចជា ទីតាំងរោងម៉ាស៊ីន ផលិតភាពរបស់រោងម៉ាស៊ីន និងទីតាំងសហគមន៍ផលិតពូជស្រូវនៅទូទាំងប្រទេស។

• បណ្តុះបណ្តាលនិស្សិត និងយុវជនអំពីរបៀបនៃការគូសផែនទីដីស្រែរបស់ប្រជាកសិករ

• បណ្តុះបណ្តាលនិស្សិត និងយុវជនអំពីរបៀបនៃការប្រើប្រាស់កម្មវិធី Sirrus និងកម្មវិធី SST Submit សម្រាប់អនុវត្តក្នុងកសិដ្ឋាន និង

សហគមន៍កសិករ

• បណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗក្នុងវិស័យកសិកម្ម ដើម្បីដាក់បញ្ចូលប្រព័ន្ធបច្ចេកវិទ្យាថ្មី ដោយភ្ជាប់ជាមួយត្រាក់ទ័រក្នុងការគ្រប់គ្រង ប្រតិបត្តិ និងប្រមូលព័ត៌មាន។

• កសាងផែនទីសហគមន៍ផលិតពូជស្រូវ ទីតាំងរោងម៉ាស៊ីន ផែនទីតំបន់ និងផែនទីដីស្រែរបស់សហគមន៍កសិករ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ស្វែងរក និងបង្ហាញព្រមទាំងធ្វើស្ថិតិទិន្នផលកសិកម្មក្នុងទំហំធំ។

# ការវិវត្តន៍នៃស្ថានភាពនៃបញ្ហាប្រឈមនៃពូជ និងការដាំដុះស្រូវ

បច្ចុប្បន្នភាពនៃវិស័យដំណាំស្រូវក្នុងប្រទេសកម្ពុជានៅមានភាពខ្វះខាត ជាច្រើនដែលទាមទារអោយមានការយកចិត្តទុកដាក់ជាបន្ទាន់ពីភាគីដែលពាក់ព័ន្ធជាពិសេសរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## អំពីពូជ

ពូជស្រូវជាធាតុចូលមួយដ៏សំខាន់សម្រាប់ដំណាំស្រូវក្នុងការបង្កើនប្រសិទ្ធភាពនៃផលិតកម្មស្រូវ ដូចជា ទិន្នផល គុណភាពស្រូវ តម្រូវការទីផ្សារដែលជា កត្តាជំរុញ អោយមានតម្លៃខ្ពស់បន្ទាប់ពីច្រូតកាត់ ប្រសិនបើកសិករជ្រើសរើសពូជស្រូវអោយបានត្រឹមត្រូវ។ តែភាពជាក់ស្តែងបច្ចុប្បន្ននេះប្រជាពលរដ្ឋនៅមិនទាន់ជ្រើសរើសពូជបានត្រឹមត្រូវនៅឡើយទេព្រោះ៖

១ - ស្ថានភាពទីផ្សារស្រូវមិនទាន់មានភាពទុកចិត្តបានដោយការគ្រប់គ្រងមិនទាន់មានភាពល្អប្រសើរ ដែលធ្វើអោយតម្លៃស្រូវនៅមិនទាន់មានតម្លាភាពសំរាប់កសិករ ដោយតម្លៃមិនសូវខុសគ្នារវាងអ្នកប្រើពូជល្អ និងមិនល្អ

២- ពុំទាន់មានការផ្សព្វផ្សាយពូជអោយបានធំទូលាយក្នុងរូបភាពពាណិជ្ជកម្មនៅឡើយទេ

៣ - យុទ្ធសាស្រ្តពូជស្រូវបច្ចុប្បន្នពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារពាណិជ្ជកម្មនាំចេញនៅឡើយ ដូចជា ប្រភេទពូជដែលជ្រើសរើសបច្ចុប្បន្ន ផលិតកម្មពូជមិនទាន់គ្រប់គ្រាន់ ពុំមានប្រព័ន្ធច្បាប់ និងនិតិវិធីគ្រប់គ្រងការផលិត និងចែកចាយ

៤- កសិករមិនទាន់មានលក្ខណៈគ្រប់គ្រាន់ សម្រាប់បង្កើនអោយមានការវិនិយោគពីវិស័យឯកជនទៅលើកការផលិតពូជ ដោយសារទំហំនៃការផលិតស្រូវរបស់កសិករ មិនទាន់មានលក្ខណៈពាណិជ្ជកម្មទ្រង់ទ្រាយធំ។

## អំពីផលិតកម្មស្រូវ

ផលិតកម្មស្រូវនៅមានលក្ខណៈមិនគ្រប់គ្រាន់នៅឡើយសម្រាប់ឆ្លើយតបទៅ នឹងតម្រូវការទីផ្សារអន្តរជាតិទាំងគុណភាពក្នុងបរិមាណច្រើនទាំងសមត្ថភាពផលិត។ ទាំងនេះដោយសារតែស្ថានមួយចំនួន ដែលធ្វើអោយផលិតកម្មនៅមិនទាន់មានការកែប្រែដូចជា៖

១- សមត្ថភាពភាពចងក្រង និងលើកកំពស់សហគមន៍ កសិករ ឬសហគមន៍ដែលមានស្រាប់នៅមានភាពទន់ខ្សោយនៅឡើយ

២ - ពុំទាន់មានភាពទុកចិត្តសំរាប់ការជម្រុញការផលិតដោយនៅមានភាពខ្វះខាតមួយចំនួន ដូចជាការប្រកួតប្រជែងលើទីផ្សារ សមត្ថភាពប្រមូលទិញ (ការទុកដាក់ ការសម្ងួត ទុនបង្វិល) ដែលជា កត្តាធ្វើអោយមានភាពរុញសំរាប់អ្នកផលិតជាពិសេសកសិករដំណាំស្រូវ។

៣- សមត្ថភាពអនុវត្តបច្ចេកទេសក្នុងការផលិតស្រូវនៅមានកំរិតដែលធ្វើអោយទិន្នផលិតទាប និងគុណភាពមិនទាន់ល្អគ្រប់គ្រាន់

៤- សហគមន៍កសិករដែលមានស្រាប់ពុំទាន់មានការគ្រប់គ្រងបានល្អគ្រាន់នៅឡើយ

៥- ការអនុវត្តក្នុងផលិតកម្មស្រូវពុំទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលយកបច្ចេកវិទ្យាទំនើបនៅឡើយ

៦- ហេដ្ឋារចនាសម្ព័ន្ធកសិកម្មមិនទាន់មានភាពល្អនៅឡើយដូចជា ប្រព័ន្ធស្រោចស្រពប្រព័ន្ធដីស្រែជាដើម៕



# ព័ត៌មានអំពីដៃគូអភិវឌ្ឍន៍ និងសមាជិកសំខាន់ៗ

## ស្វែងយល់អំពីកម្មវិធីអ៊ិម អូ ស៊ី ១០១ Incubator របស់ក្រសួងពាណិជ្ជកម្ម





នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បាន អញ្ជើញ ជាអធិបតីក្នុងវគ្គផ្តាច់ព្រ័ត្រ លើការធ្វើបទបង្ហាញពីគំនិតអាជីវកម្មទៅកាន់វិនិយោគិន ក្នុងកម្មវិធីអ៊ិម អូ ស៊ី ១០១ Incubator ដែលជាគំនិតផ្តួចផ្តើមមួយរបស់ក្រសួងពាណិជ្ជកម្ម មានគោលបំណងផ្តល់ការអប់រំ និងលើកទឹកចិត្តដល់ការចាប់ផ្តើមដំណើរការអាជីវកម្មដំបូងរបស់សហគ្រិន តាមរយៈការបណ្តុះបណ្តាល និងប្រឹក្សាយោបល់។

**កម្មវិធីអ៊ិម អូ ស៊ី ១០១** Incubator នាំមកនូវចំណេះដឹងថ្មីៗជូនដល់សហគ្រិនកម្ពុជាពី របៀបរៀបចំ លក់ផលិតផល និង ពង្រីកអាជីវកម្មថ្មី ឬអាជីវកម្មដែលមានស្រាប់សម្រាប់វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងវេទិកាលក់ទំនិញក្នុងពេលអនាគត។
កម្មវិធីនេះរៀបចំឡើងដើម្បីកសាងសមត្ថភាពអាជីវករ ពាណិជ្ជករ តាមរយៈការផ្តល់នូវគោលគំនិតល្អៗសំខាន់ៗ ទៅលើការចាប់ផ្តើមអាជីវកម្មដំបូង និងអាជីវកម្មដែលមានស្រាប់ តាមការបណ្តុះបណ្តាល និងហ្វឹកហ្វឺនផ្សេងៗ។
កម្មវិធីនេះចែកចេញជាបួនដំណាក់កាលរួមមាន៖ វគ្គចាប់ផ្តើមដំបូង (Boot Camp) វគ្គបណ្តុះបណ្តាលភ្ញាស់គំនិតអាជីវកម្ម (Incubation) វគ្គការផ្សព្វផ្សាយនៅលើទីផ្សារ (Market Day) និងវគ្គផ្តាច់ព្រ័ត្រ (Final Pitch) ផ្តល់ចំណេះដឹងកាន់តែស៊ីជម្រៅអំពីសារសំខាន់នៃការបង្ហាញគំនិតអាជីវកម្មទៅទៅសហគ្រិន ការកសាងផែនការអាជីវកម្មដ៏រឹងមាំក្នុងក្របខណ្ឌការងារ ដើម្បីវាយតម្លៃលទ្ធភាពជោគជ័យរយៈពេលវែង របៀបស្វែងរកមូលនិធិគាំទ្រគម្រោងអាជីវកម្ម វិធីស្វែងរកទីផ្សារតាមប្រព័ន្ធអនឡាញ និងកត្តាដទៃទៀតជម្រុញឲ្យការចាប់ផ្តើមអាជីវកម្មមួយទទួលបានជោគជ័យនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។

សហគ្រិនដែលជាបេក្ខជនចំនួន ៨៩ក្រុម ក្នុងចំណោម ១៤៥ក្រុម ពីវគ្គ Boot Camp ទាំងបួនផ្នែក រួមមាន៖
"**សហគ្រិនដែលមានគំនិតច្នៃប្រឌិត**" "**សហគ្រិនផ្នែកកសិកម្ម**" "**សហគ្រិនផ្នែកអាជីវកម្មទូទៅ**" និង "**សហគ្រិនផ្នែកបច្ចេកវិទ្យា**" ត្រូវបានជ្រើសរើសឲ្យចូលរួម ក្នុងវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនភ្ញាស់គំនិតផ្នែកអាជីវកម្ម។ វគ្គបណ្តុះបណ្តាលដែលមាន ៦ប្រធានបទនេះ ត្រូវបានបង្រៀនដោយបណ្តាសហគ្រិនជោគជ័យបំផុតរបស់កម្ពុជា រយៈពេលពីរខែ។ សហគ្រិនចំនួន៤៥ក្រុម ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលខាងលើដោយជោគជ័យ ត្រូវបានអនុញ្ញាត ឲ្យចូលរួមប្រកួតប្រជែងវគ្គផ្សព្វផ្សាយទីផ្សារ ដោយដាក់បង្ហាញផលិតផល និងសេវាកម្មរបស់ខ្លួនរៀងៗខ្លួន នាឱកាសនៃកម្មវិធីតាំងពិព័រណ៍ ភូមិមួយផលិតផលមួយ កាលពីចុងឆ្នាំ២០១៥។

នៅក្នុងកម្មវិធីធ្វើបទបង្ហាញចុងក្រោយ ១៧ក្រុមបេក្ខជនឆ្នើមជាងគេ នឹងមានរយៈពេល១០នាទី ជាឱកាសធ្វើបទបង្ហាញចំពោះមុខបណ្តាវិនិយោគិនដ៏មានសក្តានុពលរបស់កម្ពុជា ក្នុងការប្រកួតប្រជែង ធ្វើយ៉ាងណាទាក់ទាញដល់វិនិយោគិនទាំងនោះឲ្យផ្តល់ការសហការគាំទ្រធ្វើពាណិជ្ជកម្ម និងផ្តល់នូវមូលនិធិហិរញ្ញប្បទានដល់ពួកគេ។ ក្រុមបេក្ខជននីមួយៗ អាចស្វែងរកឱកាសក្នុងការបង្កើតទំនាក់ទំនងអាជីវកម្មពាណិជ្ជកម្ម នៅក្នុងអំឡុងពេលសម្រាកញ៉ាំអាហារសម្រន់ ដែលមានការចូលរួមពីអាជីវករ និងពាណិជ្ជកម្ម ប្រមាណជាង១០០នាក់ផងដែរ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានសម្តែងការកោតសរសើរ និងថ្លែងអំណរគុណ ដល់គណៈវិនិច្ឆ័យ គ្រូបង្គោលផ្តល់ប្រឹក្សា គ្រូបង្រៀន អ្នកចូលរួម និងអ្នកចាត់ចែងកម្មវិធី ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការធ្វើឲ្យកម្មវិធីអ៊ិម អូ ស៊ី ១០១ Incubatorនេះទទួលបានជោគជ័យ។ ឯកឧត្តមទេសរដ្ឋមន្ត្រី សង្ឃឹមថា៖ អ្នកចូលរួមទាំងអស់ ដែលបានឈានដល់ដំណាក់កាលនៃការធ្វើបទបង្ហាញចុងក្រោយនៅថ្ងៃនេះ នឹងបានសិក្សាជំនាញដែលចាំបាច់ដើម្បី ទាក់ទាញវិនិយោគិនក្នុងការជួយឲ្យពួកគេចាប់ផ្តើមដំណើរការអាជីវកម្មដំបូង និងពង្រីកអាជីវកម្មរបស់ខ្លួន។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានថ្លែងប្រាប់ក្រុមដែលចូលរួមផងដែរថា៖ ក្រសួងប្តេជ្ញាធ្វើយ៉ាងណាឲ្យច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចនេះត្រូវបានអនុម័តនៅក្នុងឆ្នាំនេះ ដើម្បីគាំទ្រដល់អាជីវកម្មរបស់ពួកគេ៕

# ស្វែងយល់អំពី វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) និង បរិដ្ឋកម្មដំណាំស្រូវនៅកម្ពុជា

*(ដោយណ្ឌិត អ៊ុក ម៉ាការា)*

**១. ប្រវត្តិ:**

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧៤ អនក្រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ដើម្បីបន្តនូវការងារអភិវឌ្ឍន៍ដំណាំស្រូវពីគម្រោងកម្ពុជា អ៊ីរី អូស្ត្រាលី និងចាប់ផ្តើមការងារស្រាវជ្រាវនិងអភិវឌ្ឍន៍លើដំណាំកសិកម្មក្រៅពីស្រូវ ដែលបានសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការណ៍នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០០ ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងលោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី** ហ៊ុន សែន ព្រមទាំងសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនាថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៧ ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**។

**២. អំពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា:**

កាឌីជាគ្រឹះស្ថានសាធារណរដ្ឋបាល មានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលហិរញ្ញវត្ថុ និងដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាព១១ រូប មកពីស្ថាប័នពាក់ព័ន្ធចំនួន៧ មានអាណត្តិ៣ឆ្នាំ ព្រមទាំងនាយកប្រតិបត្តិមួយរូប។ ក្នុងក្របខ័ណ្ឌជាគ្រឹះស្ថានសាធារណរដ្ឋបាល កាឌីទទួលពីរដ្ឋនូវអំណាចនិងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញនូវភារកិច្ចដូចតទៅ៖

- ដឹកនាំនិងសម្រេចរាល់សកម្មភាពស្រាវជ្រាវនិងពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍកសិកម្ម
- ធ្វើការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសេដ្ឋកិច្ចកសិកម្ម មានជាអាទិ៍៖

  + បច្ចេកទេសប្រើប្រាស់ដីកសិកម្ម ការប្រើប្រាស់ជីគ្រប់ប្រភេទ ចូលរួមការកែលម្អនិងថែរក្សានិរន្តរភាពគុណភាពដី

  + បង្កើតនិងបន្សាំពូជថ្មីល្អៗ ប្រកបដោយសក្តានុពលសេដ្ឋកិច្ចខ្ពស់ ទិន្នផលខ្ពស់ ធន់នឹងជំងឺនិងសត្វល្អិតចង្រៃ និងមានគុណភាពសមស្របតាមតម្រូវការរបស់ទីផ្សារនិងការបរិភោគ

  + អភិវឌ្ឍបច្ចេកទេសការពារដំណាំ មានការប្រើប្រាស់ថ្នាំពុលកសិកម្មផ្សេងៗ ការប្រើប្រាស់វិធានការចម្រុះ "មេកានិក ជីវសាស្ត្រ ថ្នាំ" បង្កើនប្រសិទ្ធភាពក្នុងកិច្ចការពារដំណាំ ប្រឆាំងកត្តាចង្រៃផ្សេងៗផង បន្ថយគ្រោះថ្នាក់ចំពោះសុខភាព ពលករកសិកម្មនិងអ្នកបរិភោគផង និងចូលរួមថែរក្សាតុល្យភាពនៃបរិស្ថានធម្មជាតិផង

  + ការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្មទំនើបៗ ឈានទៅអភិវឌ្ឍយន្តូបនីយកម្មជាជំហានៗក្នុងវិស័យកសិកម្ម

  + ប្រព័ន្ធកសិកម្មចម្រុះចូលរួមបង្កើននិងធានាសុវត្ថិភាពប្រាក់ចំណូល សំដៅលើកស្ទួយកម្រិតជីវភាពរបស់កសិករ។
- ផ្តល់សេវាទ្រទ្រង់ដល់ការកសាងនិងការអនុវត្តន៍គម្រោងអភិវឌ្ឍន៍កសិកម្មផ្សេងៗ តាមការសិក្សាលើលក្ខណៈវិនិច្ឆ័យ ការតាមដាន និងការវាយតម្លៃផ្នែកបច្ចេកទេសនិងសេដ្ឋកិច្ច ស្របទៅនឹងតម្រូវការរបស់ស្ថាប័នឬបុគ្គលពាក់ព័ន្ធ ជាពិសេសកសិករ។
- អភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្មតាមរយៈការរៀបចំសិក្ខាសាលា ទស្សនកិច្ចសិក្សា កម្មសិក្សា និងអង្គប្រជុំផ្សេងៗទៀត ។ល។
- ធ្វើទំនាក់ទំនងជាមួយបណ្តាស្ថាប័នស្រាវជ្រាវលើសកលលោក រៀបចំនិងចូលរួមកិច្ចប្រជុំជាមួយអង្គការអន្តរជាតិនានា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការស្រាវជ្រាវនិងផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានបច្ចេកវិទ្យា វិទ្យាសាស្ត្រ សេដ្ឋកិច្ចតាមតម្រូវការ និងការចាំបាច់។

www.cardi.org.kh



# កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់(RED III) បានធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនង និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅក្នុងវិស័យស្រូវ/អង្ករខេត្តសៀមរាប



កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់(RED III) បានធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនង និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅក្នុងវិស័យស្រូវ/អង្ករខេត្តសៀមរាប កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED III) គឺកម្មវិធីអភិវឌ្ឍន៍ជនបទមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគាំទ្រ ដោយរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ និងស្វីស។ កម្មវិធីនេះបានចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ២០១៤ រហូតដល់ខែធ្នូ ឆ្នាំ២០១៧ និងមានវិសាលភាពចំនួនបីខេត្ត គឺសៀមរាប បន្ទាយមានជ័យ និងឧត្តរមានជ័យ។ កាលពីមុនកម្មវិធីមានឈ្មោះថា កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់-ក្រវាត់បៃតង បានអនុវត្តចាប់ពីខែតុលា ឆ្នាំ២០០៧ រហូតដល់ ខែសីហា ឆ្នាំ ២០១៤ នៅតែក្នុងខេត្តសៀមរាបប៉ុណ្ណោះ។

កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED III) មានគោលដៅចំបងគឺ «ប្រជាជននៅតាមជនបទក្រីក្រ - ជាពិសេសស្ត្រី ប្រើប្រាស់ឱកាសការងារ និងឱកាសអាជីវកម្មថ្មីៗ ដែលមាននិរន្តរភាពដើម្បីបង្កើនប្រាក់ចំណូលរបស់ខ្លួន និងកាត់បន្ថយភាពក្រីក្រ»។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធីផ្តោតលើសកម្មភាពការងារសំខាន់ៗបីផ្នែកធំៗ៖ ទី១ អភិវឌ្ឍ សមត្ថភាពរដ្ឋបាលមូលដ្ឋានក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ទី២ បង្កើនកិច្ចសហការរវាងអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងទី៣ បង្កើតសេវាកម្ម និងការភ្ជាប់ទំនាក់ទំនងអាជីវកម្មដើម្បីបង្កើនភាពប្រកួតប្រជែងរបស់ផលិតផលក្នុងស្រុក។

ក្នុងការដោះស្រាយបញ្ហារបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវដែលមិនអាចរកទិញស្រូវមានគុណភាពពីកសិករ និងដោះស្រាយបញ្ហាកសិករដែលមិនទាន់យល់ពីមូលហេតុដែលពួកគាត់ទទួលបានតម្លៃស្រូវទាប កម្មវិធីបានសម្របសម្រួលឲ្យមានកិច្ចសន្ទនាពហុភាគីពាក់ព័ន្ធ (MSD) សម្រាប់ភាគីទាំងពីរដើម្បីបានពិភាក្សា ចែករំលែក និងស្វែងរកដំណោះស្រាយដោយខ្លួនឯង។

កិច្ចសន្ទនាពហុភាគី គឺជាឧបករណ៍មួយដែលអាចយកមកប្រើប្រាស់ក្នុងកាលៈទេសៈដែលទាមទារឲ្យមានទំនាក់ទំនង និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធផ្សេងៗដើម្បីរួមគ្នាដោះស្រាយបញ្ហា និងការប្រឈមនានា ជាពិសេសសម្រាប់បុគ្គល ឬក្រុមដែលមិនសូវមានទំនាក់ទំនង ឬមិនធ្លាប់សហការជាមួយគ្នាកន្លងមក ឬមានការសង្ស័យរវាងគ្នាទៅវិញទៅមក។ កិច្ចសន្ទនាពហុភាគី កសាងទំនុកចិត្តក្នុងចំណោមអ្នកពាក់ព័ន្ធ ដោយជួយអ្នកពាក់ព័ន្ធឲ្យធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួម និងបង្កើនថាមភាព(synergies) សម្រាប់ផលប្រយោជន៍រួម មានន័យថា នៅទីបំផុត អ្នកពាក់ព័ន្ធ មានការឯកភាពគ្នាមួយដែលឈានដល់ស្ថានភាពឈ្នះ-ឈ្នះសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។

ក្នុងបរិបទកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED III) ដំណើរការកិច្ចសន្ទនាពហុភាគីនៅក្នុងវិស័យស្រូវអង្ករខេត្តសៀមរាប បានចាប់ផ្តើមពីការពិភាក្សាក្រៅផ្លូវការជាមួយអ្នកពាក់ព័ន្ធនៅក្នុងផលិតកម្មស្រូវ ការទិញលក់ស្រូវ និងការកែច្នៃ។ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញស្រូវបានឲ្យដឹងថា គុណភាពស្រូវអាស្រ័យលើកត្តាបីគឺ ភាពសុទ្ធ ស្ងួត និងស្អាត។ ប្រសិនបើកសិករចង់ចរចាបានតម្លៃល្អ ពួកគាត់ត្រូវតែធ្វើតាមចំណុចទាំងបីចំណុចនេះ។ មន្ទីរកសិកម្មខេត្តសៀមរាប ក៏បានផ្តល់ព័ត៌មានបច្ចេកទេសទេសចាំបាច់មួយចំនួនសម្រាប់កសិករយកទៅកែលម្អផលិតកម្មស្រូវដើម្បីឆ្លើយតបនឹងគុណភាពខាងលើផងដែរ។ ក្រៅពីនេះ ការពិភាក្សាក្រៅផ្លូវការជាមួយអ្នកក្រុមអ្នកពាក់ព័ន្ធផ្សេងៗទៀតបានឲ្យដឹងថា មានអ្នកទិញមួយចំនួនបានប្រើប្រាស់ជញ្ជីងមិនត្រឹមត្រូវដែលធ្វើឲ្យបាត់ទំងន់រហូតដល់២០% នៃទំងន់សរុប ហើយក៏មានកសិករមួយចំនួនដែរដែលលក់ស្រូវសើមទឹក ឬដាក់ថ្ម ឬខ្សាច់ក្នុងការ៉ុងដើម្បីបង្កើនទំងន់។ ទោះបីយ៉ាងណាក៏ដោយ ក៏មានម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដែលបានបង្ហាញពីចំណាប់អារម្មណ៍លើការប្រើប្រាស់ជញ្ជីងត្រឹមត្រូវ និងកសិករដែលមានទឹកចិត្តក្នុងការផលិតស្រូវដែលមានគុណភាព "**សុទ្ធ ស្ងួត និងស្អាត**" នេះផងដែរ។

ដើម្បីចាប់ផ្តើមការសន្ទនា អ្នកពាក់ព័ន្ធសកម្ម និងមានឆន្ទៈត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំមួយ ដែលរៀបចំឲ្យមានម្ខាងជាកសិករ និងម្ខាងទៀតជាអ្នកទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ កសិករបានលើកឡើងពីតម្លៃស្រូវទាប ចំណែកឯអ្នកទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវលើកឡើងអំពីបញ្ហាគុណភាពស្រូវដែលត្រូវការដើម្បីកិនជាអង្ករតម្រូវតាមទីផ្សារ និងបានតម្លៃខ្ពស់។
ក្នុងពេលជួបគ្នាសន្ទនាលើកដំបូងនេះ កសិករ អ្នកទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវបានពិភាក្សាគ្នាអំពីការកំណត់គុណភាពស្រូវដែល មានទីផ្សារល្អ របៀបពិនិត្យគុណភាពស្រូវ និងបច្ចេកទេសផលិតកម្មដែលត្រូវអនុវត្តដើម្បីកែលម្អគុណភាពស្រូវ។
ការពិភាក្សាគ្នាដោយបើកចំហបែបនេះ បានធ្វើឡើងដោយភាគីនីមួយៗលើកឡើងអំពីថ្លៃដើមចំណាយ រៀងៗខ្លួន ដើម្បីឲ្យបានដឹងទាំងអស់គ្នាអំពីកម្រិតលទ្ធភាពចំណេញ។ មិនតែប៉ុណ្ណោះ ការទិញលក់ស្រូវដែលមិនស្មោះត្រង់នឹងគ្នា ក៏ត្រូវបានលើកមកពិភាក្សាដោយចំហផងដែរ។ អ្វីដែលបានពិភាក្សាគ្នារវាងកសិករ និងអ្នកទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ គឺមូលដ្ឋានសំខាន់មួយសម្រាប់ការព្រមព្រៀងគ្នានៅជំហានបន្ទាប់ ដោយសារកសិករបានសំដែងនូវឆន្ទៈរបស់ខ្លួនក្នុងការកែលម្អគុណភាព ចំណែកឯម្ចាស់រោងម៉ាស៊ីន និងអ្នកទិញស្រូវក៏



(ត ទៅទំព័រទី ១៩)

(ត មកពីទំព័រទី ១៨)



មានទឹកចិត្តក្នុងផ្តល់តម្លៃល្អទៅតាមគុណភាព ព្រមទាំងប្រើប្រាស់ជញ្ជីងត្រឹមត្រូវ និងឧបករណ៍វាស់សំណើមស្រូវ ដែលទទួលស្គាល់ដោយមន្ទីរឧស្សាហកម្មខេត្ត។



នៅក្នុងកិច្ចសន្ទនាលើកទីពីរដែលមានការចូលរួមពីប្រធានសមាគម ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងភាគច្រើនជាកសិករ បានកំណត់រួមគ្នានូវលក្ខណៈវិនិច្ឆ័យគុណភាពស្រូវ ដោយប្រើប្រាស់ប៉ាន់ស្រូវដែលយកមកដោយកសិករ។ ការសន្ទនាលើកចុងក្រោយ បានឈានដល់ការព្រមព្រៀងមួយដែលបញ្ជាក់ពីលក្ខណៈវិនិច្ឆ័យគុណភាពស្រូវច្បាស់លាស់។
ម្ចាស់រោងម៉ាស៊ីនកិនស្រូវក៏សន្យានឹងផ្តល់តម្លៃតាមទីផ្សារ និងតម្លៃបន្ថែម ព្រមទាំងប្រើប្រាស់ជញ្ជីងត្រឹមត្រូវពេលទិញលក់ស្រូវ។
ការព្រមព្រៀងគ្នាលើកដំបូងត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ២០០៨ ហើយមានការទិញលក់ស្រូវចំនួន ៨លើកដែលមានស្រូវចំនួន ៦៤តោន ត្រូវបានធ្វើឡើងដោយផ្អែកលើកការព្រមព្រៀងគ្នានេះ។ នៅរដូវបន្ទាប់ កសិករដែលផលិតស្រូវស្របតាមគុណភាព និងលក់តាមការព្រមព្រៀងគ្នា អាចបង្កើនប្រាក់ចំណេញរហូតដល់២០%។

មានលទ្ធផលជាច្រើនបានលេញចេញជាបន្តបន្ទាប់ពីកិច្ចសន្ទនា និងការព្រមព្រៀងគ្នានេះ ដូចជាម្ចាស់រោងម៉ាស៊ីនកិនស្រូវដទៃដែលមិនធ្លាប់ចូលរួមក្នុងដំណើរការនេះ ក៏បានឯកភាពប្រើប្រាស់លក្ខណៈវិនិច្ឆ័យគុណភាពស្រូវ និងជញ្ជីងត្រឹមត្រូវផងដែរចំណែកកសិករដែលចូលរួមក្នុងការព្រមព្រៀងគ្នានេះ ក៏ចាប់ផ្តើមមានកម្លាំងចរចារ និងបដិសេធមិនលក់ឲ្យអ្នកទិញណាដែលផ្តល់លក្ខខណ្ឌទិញលក់មិនសមរម្យ។ ពីមួយឆ្នាំទៅមួយឆ្នាំ ទំនុកចិត្តរវាងអ្នកពាក់ព័ន្ធដែលចូលរួមក្នុងការសន្ទនាតាំងពីដំបូង បន្តកើនឡើងជាលំដាប់។

ការសន្ទនាគ្នាជាប្រចាំបែបនេះ មិនត្រឹមតែជាវេទិកាណែនាំការព្រមព្រៀងគ្នាដែលបានអនុវត្តកន្លងមកដល់អ្នកពាក់ព័ន្ធដទៃៗទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាវេទិកាមួយដែលអ្នកពាក់ព័ន្ធបានពិភាក្សាពីបញ្ហាផ្សេងៗទៀតទាក់ទងនឹងវិស័យស្រូវអង្ករទាំងមូលនៅក្នុងប្រទេសកម្ពុជា។ ក្រុមអ្នកពាក់ព័ន្ធចូលរួមក្នុងដំណើរការនេះមានទំនាក់ទំនង និងការសហការជិតស្និទ្ធ ដោយសារពួកគាត់ដឹងពីតួនាទីរៀងៗខ្លួន។

លើសពីនេះ មានគំនិតផ្តួចផ្តើមច្រើនទៀតដែលអាចលើកឡើង និងអនុវត្តដោយអ្នកពាក់ព័ន្ធ ដូចជាយុទ្ធនាការផ្សព្វផ្សាយអំពីការប្រើប្រាស់ពូជស្រូវសុទ្ធដើម្បីបង្កើនទិន្នផល និងទទួលបានស្រូវមានគុណភាព ដែលបានធ្វើនៅឆ្នាំ២០១១។ ចាប់តាំងពីឆ្នាំនោះមករហូតដល់បច្ចុប្បន្ន មានកសិករលើសពី១៥០នាក់ដែលហ៊ានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីទិញស្រូវពូជគ្រឹះ និងពូជបញ្ជាក់ពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា( កាឌី) មកផលិតស្រូវពូជលក់ចែកចាយទាំងក្នុង និងក្រៅខេត្ត ដោយទទួលបានការគាំទ្របច្ចេកទេសផ្ទាល់ពីមន្ទីរកសិកម្មខេត្ត។ ថ្មីៗនេះអ្នកពាក់ព័ន្ធនឹង វិស័យស្រូវអង្ករក្នុងខេត្តសៀមរាបបានលើកឡើងគម្រោងថ្មីចំនួន៣៖ទី១ គម្រោងសហការគ្នាផ្សព្វផ្សាយស្រូវពូជដែលផលិតនៅក្នុងស្រុកប៉ែកខាងលិចនៃខេត្តសៀមរាប (ពួក វ៉ារិន ក្រឡាញ់ អង្គរជុំ) ទី២ គម្រោងបង្កើនផលិតកម្ម ស្រូវគុណភាព និងបង្កើតរួមគ្នានូវសញ្ញាសម្គាល់គុណភាពស្រូវ និងទី៣ បណ្តាញអ្នកពាក់ព័ន្ធស្រូវអង្ករ។៕



## ការផ្លាស់ប្តូរពី កសិករ ទៅជាសេដ្ឋីស្រុកស្រែ

*(បណ្ឌិត យ៉ង សាំងកុមារ)*

ក្នុងចន្លោះពេលឆ្នាំ ២០១៥ ដល់ ឆ្នាំ ២០២២ អង្គការសេដាក បាននឹងកំពុងអនុវត្តកម្មវិធីអភិវឌ្ឍន៍ ១០ឆ្នាំ ដែលផ្តោតទៅលើការគាំទ្រកសិករ ដើម្បីអភិវឌ្ឍន៍ខ្លួនឈានជាសេដ្ឋីស្រុកស្រែ (ផែនការ ស២២)។ ភាពជោគជ័យរបស់សេដ្ឋីស្រុកស្រែ ត្រូវវាស់តាមគោលការណ៍ សមចល ដូចខាងក្រោមនេះ៖

១. សុខភាព (សុខភាពផ្លូវកាយ និង ផ្លូវចិត្ត)
២. មិត្តភាព និង មុខមាត់ក្នុងសង្គម
៣. ចំណេះ (ចំណេះដឹង ចំណេះធ្វើ ចំណេះមើល/ គិត)
៤. លុយ (ជាពិសេស លុយសប្បាយ )។

ដើម្បីឲ្យកសិករអ្នកស្រែក្លាយជាសេដ្ឋីស្រុកស្រែ អង្គការសេដាកធ្វើការគាំទ្រដល់ពួកគាត់ ឲ្យធ្វើការផ្លាស់ប្តូរនូវ ៥ផ្នត់គំនិតសំខាន់ៗ ដូចខាងក្រោម [ថ្នាំទិព្វ ៥គ្រាប់ ] ៖

**១. ការគិតវិជ្ជមាន៖** ការផ្លាស់ប្តូរពីការគិតអវិជ្ជមាន (ការ គិតខ្លី គិតតូច គិតចង្អៀត) ទៅការគិតវិជ្ជមាន (គិតធំ គិតវែងឆ្ងាយ និងគិតទូលាយ)។
**២. ការគិតឧត្តមភាព៖** ការប្តូរពីធ្វើស្រែឃ្លោកទៅធ្វើស្រែខ្លឹម ឬការប្តូរពីការធ្វើស្រែលើដីធំ អត់ចំណេញ មកធ្វើស្រែ ឬប្រកបមុខរបរកសិកម្មលើដីតូចបានផលចំណេញខ្ពស់។
**៣. ការគិតច្នៃប្រឌិត៖** ប្តូរពីការលក់ស្រូវ ទៅលក់អង្ករ ដើម្បីបានតម្លៃខ្ពស់ និងបានអង្កាម កន្ទក់ ចុងអង្ករ សម្រាប់ប្រើប្រាស់បង្កើនប្រាក់ចំណូល និងនិរន្តរភាពប្រព័ន្ធកសិកម្ម។
**៤. ការគិតសន្សំដើម្បីវិនិយោគ៖** ប្តូរពីចាយមុនសន្សំ ទៅសន្សំមុនចាយដើម្បីបានទុនច្រើនអាចពង្រីកមុខរបរ និងសល់លុយសប្បាយចាយពេលអនាគត។
**៥. ការគិតជាប្រព័ន្ធ៖**
ការប្តូរពីធ្វើការតែឯងមកធ្វើការជាសហគមន៍ជាពិសេស សហគមន៍សន្សំ សហគមន៍ផលិត សហគមន៍ម៉ាស៊ីនកិនស្រូវ និងសហគមន៍អ្នកប្រើប្រាស់ទឹក។

កសិករដែលមានចំណាប់អារម្មណ៍ កម្មវិធីសេដ្ឋីស្រុកស្រែហើយស្ម័គ្រចិត្តប្រើប្រាស់ថ្នាំទិព្វទាំង ៥គ្រាប់ ដូចរៀបរាប់ខាងលើ និងត្រូវទទួលស្វាគមន៍ឲ្យចូលរួមក្នុងកម្មវិធី **ស ២២** របស់អង្គការសេដាក។




## ម្រេចកំពតជាទំនិញសម្គាល់ភូមិសាស្រ្តដំបូងនៅក្នុងតំបន់




មន្រ្តីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្ម បានអះអាងថា ម្រេចកំពតគឺជាផលិតផលកសិកម្មដំបូងគេក្នុងតំបន់អាស៊ាន ដែលទទួលបានការចុះបញ្ជីកម្មសិទ្ធិបញ្ញា និងការទទួលស្គាល់ជាអន្តរជាតិតាមរយៈការចុះបញ្ជីទំនិញសម្គាល់ភូមិសាស្រ្តកាលពីឆ្នាំ២០១០។

ឯកឧត្តម **អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម មានប្រសាសន៍កាលពេលថ្មីៗនេះថា ម្រេចកំពត គឺជាទំនិញសម្គាល់ភូមិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា និងជាទំនិញសម្គាល់ភូមិសាស្ត្រដំបូងគេបំផុតក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍( A S E A N ) ដែលនឹងទទួលបានការការពារនៅក្នុងសហគមន៍អឺរ៉ុប(EU)។
ម្រេចកំពតដែលត្រូវបានគេ ដាំភាគច្រើននៅក្នុងស្រុកកំពង់ត្រាចនៃខេត្តកំពត និងខេត្តកែប នោះធ្លាប់ទទួលបានវិញ្ញាបនប័ត្រទំនិញសម្គាល់ភូមិសាស្រ្តទៅលើគុណភាពខ្ពស់ ពីប្រទេសបារាំង កាលពីខែមេសា ឆ្នាំ2010។ ចាប់តាំងពីពេលនោះមកទិន្នផលម្រេចកំពតដែលប្រមូលចេញពីតំបន់មួយនេះ បានកើនឡើងជាលំដាប់ តាមរយៈការដាំដុះបន្ថែម និងការមានទីផ្សារល្អ។

លោក **ងួន ឡាយ** ប្រធានសមាគមលើកកម្ពស់ម្រេចកំពតបានអះអាងថា ម្រេចកំពតបានចុះបញ្ជីការពារម៉ាកយីហោរបស់ខ្លួន មិនត្រឹមតែលក្ខណៈអន្តរជាតិនោះទេ សូម្បីតែលក្ខណៈទ្វេភាគីជាមួយប្រទេសជិតខាងដូចជាប្រទេសថៃ និងប្រទេសវៀតណាម កម្ពុជាក៏បានធ្វើកិច្ចព្រមព្រៀងជាមួយដែរ។ លោកមានប្រសាសន៍ថា៖ “ យើងចុះបញ្ជីការពារម៉ាករបស់យើងដោយសារយើងបារម្ភមាន ក្រុមហ៊ុនឬសហគ្រាសណាមួយប្រើប្រាស់ម៉ាកសញ្ញារបស់យើងដើម្បីក្លែងបន្លំគុណភាព”។ លោកបានអះអាងថា៖ “ម្រេចកំពតមិនខ្លាចការប្រកួតប្រជែងផ្នែកគុណភាពនោះទេ តែអ្វី ដែលខ្លាចគឺគេប្រើម៉ាកយីហោម្រេចកំពត ទៅវេចខ្ចប់ផលិតផលរបស់គេ”។

នៅក្នុងរដូវកាលឆ្នាំ២០១៥-២០១៦ នេះផ្ទៃដីដាំដុះម្រេចកំពតនឹងមានរហូតដល់ ៤០ហិចតា ហើយតាមការព្យាករណ៍ទិន្នផលម្រេចនឹងផ្តល់ផលចន្លោះពី៧០-៨០តោន។ បរិមាណនេះបានកើនឡើងជាង ១២តោន បើធៀបទៅនឹងរដូវកាលមុនៗ ខណៈដែលផ្ទៃដីដាំដុះម្រេចដែលអាចប្រមូលផលបានកើនឡើងចំនួន ១៥ហិចតាផងដែរ។

បច្ចុប្បន្នសមាគមលើកកម្ពស់ម្រេចកំពត មានសមាជិកជិត ៣០០គ្រួសារ ដោយក្នុងនោះសមាជិកដែលអាចទទួលផលម្រេចមានចំនួន ២៤៣គ្រួសារ ហើយគ្រួសារចន្លោះពី3០-4០ទៀតបានដាក់ពាក្យចូលជាសមាជិករបស់សមាគមម្រេចកំពត។ម្រេចកំពតលក់នៅប្រទេសបារាំងមានតម្លៃ១៧០អឺរ៉ូក្នុងមួយគីឡូក្រាម ដែលប្រហាក់ប្រហែល **២៣០**ដុល្លារអាមេរិក ក្នុងមួយគីឡូក្រាម។

# សម្រង់អត្ថបទព័ត៌មានសំខាន់ៗដែលបានចុះផ្សាយនៅក្នុងសារព័ត៌មាន ក្នុងស្រុកពីខែមករា ដល់ ខែមីនា ឆ្នាំ២០១៦

## នាយករដ្ឋមន្ត្រីជំរុញភាគីពាក់ព័ន្ធឲ្យបង្កើនសមត្ថភាពស្តុក និងផលិតអង្ករនាំចេញ

*(ថ្មីៗ ៖ ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦)*

ភ្នំពេញ៖ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងក្នុងពិធីបុណ្យស្រូវអង្ករកម្ពុជា លើកទី៥ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦នេះ ជំរុញក្រសួង និងភាគីឯកជនពាក់ព័ន្ធឲ្យសិក្សាបង្កើនសមត្ថភាពប្រមូលស្តុកស្រូវ និងផលិតអង្ករល្អកម្ពុជានាំចេញទៅអន្តរជាតិ ទាំងប្រទេសក្នុងតំបន់ និងក្រៅតំបន់។ [---]

## នាយករដ្ឋមន្ត្រីព្រមានបិទក្រុមហ៊ុនដឹកជញ្ជូនលើសទម្ងន់

*(ថ្មីៗ៖ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៦)*

ពីពិធីបិទសន្និបាតបូកសរុបការងារ ប្រចាំឆ្នាំ ២០១៥ និងកំណត់ទិសដៅការងារ ឆ្នាំ២០១៦ ក្រសួងមហាផ្ទៃ នៅថ្ងៃទី២៥ ខែកុម្ភៈឆ្នាំ២០១៦នេះ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានបញ្ជាសមត្ថកិច្ចឲ្យតាមចាប់រថយន្តដឹកអង្ករបំផ្លាញស្ពានអ្នកលឿង បើទោះបីជារថយន្តគេចដល់បរទេសក៏ដោយ ក៏ត្រូវតាមចាប់មកវិញ។ លើសពីនេះ លោកបានព្រមានបិទក្រុមហ៊ុនដឹកជញ្ជូនទាំងឡាយណាដែលដឹកលើសទម្ងន់កំណត់។ ជាងនេះទៀត **សម្តេច ហ៊ុន សែន** បានស្តីបន្ទោសខ្លាំងៗ លើរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។ [---]

## គណៈកម្មការពិសេសបន្ទាន់មួយ ត្រូវបានបង្កើតឡើង ដើម្បីទប់ស្កាត់ការនាំចូលអង្ករប្រទេសជិតខាង

*(Freshnew៖ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៦)*

(ភ្នំពេញ)៖ គណៈកម្មការពិសេសបន្ទាន់មួយ ត្រូវបានសហព័ន្ធស្រូវអង្ករកម្ពុជា បង្កើតឡើង ដើម្បីជួយទប់ស្កាត់ការហូរចូលមិនស្របច្បាប់នៃអង្ករ ពីប្រទេសជិតខាង មកប្រទេសកម្ពុជា ហើយក៏ដើម្បីស្វែងរកហិរញ្ញវត្ថុ ជួយដល់វិស័យស្រូវអង្ករកម្ពុជា ពិសេសរោងម៉ាស៊ីនកិនស្រូវដែលប្រឈមមុខនឹងការបិទទ្វារ។

ការបង្កើតគណៈកម្មការនេះ ត្រូវបានបញ្ជាក់ឡើង នៅសន្និសីទសារព័ត៌មាន របស់សហព័ន្ធស្រូវអង្ករកម្ពុជា ស្តីពីផែនការដោះស្រាយបញ្ហាប្រឈម ក្នុងវិស័យស្រូវអង្ករ នៅភោជនីដ្ឋានទន្លេបាសាក់២ នៅព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៦។ **ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានថ្លែងក្នុងសន្និសីទសារព័ត៌មានថា ក្រុមការងារពិសេសដោះស្រាយបញ្ហាបន្ទាន់ ក្នុងវិស័យស្រូវអង្ករកម្ពុជានេះមានសមាសភាពមន្ត្រីជាន់ខ្ពស់របស់សហព័ន្ធ ដែលសុទ្ធសឹងតែជាអ្នកមានបទពិសោធន៍ ជាមួយនឹងវិស័យស្រូវអង្ករនេះ។ [---]

## ឯកឧត្តម ស៊ុន ចាន់ថុល ពន្យល់ពី «ចំណុចខ្លាំង-ខ្សោយនៃការទាក់ទាញវិនិយោគ»

*(ថ្មីៗ៖ ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១៦)*

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ឯកឧត្តម ស៊ុន ចាន់ថុល** ពន្យល់ពី«ចំណុចខ្លាំង និងខ្សោយនៃការទាក់ទាញវិនិយោគ»របស់កម្ពុជា។ លោកលើកឡើងថា កម្ពុជាមានប្រជាជនវ័យក្មេងច្រើន និងមានភូមិសាស្ត្រស្ថិតចំកណ្តាលសហគមន៍អាស៊ាន ដែលអំណោយផលដល់ការវិនិយោគ។ លោកបន្ថែមថា កម្ពុជាមាននយោបាយបើកចំហរការវិនិយោគផ្ទាល់ និងអនុគ្រោះពន្ធមួយចំនួនជាដើម។ ប៉ុន្តែ លោកអះអាងថា តម្លៃដឹកជញ្ជូន និងអគ្គិសនីនៅថ្លៃជាងប្រទេសជិតខាង រួមទាំងអំពើពុករលួយ និងកង្វះកម្លាំងពលកម្មជំនាញ គឺជាឧបសគ្គសម្រាប់អ្នកវិនិយោគ។ [---]

# អំពីសមាជិក ស.អ.ក

សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ជាស្ថាប័នឯកជនដែលមានសំឡេងតែមួយគត់នៃឧស្សាហកម្មស្រូវអង្ករកម្ពុជាដោយបានបង្កើតឡើង តាមរយៈការបោះឆ្នោតនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៤ ដោយសមាជិកស្ថាបនិកចំនួន **២១៣** តំណាងឲ្យសហព័ន្ធអ្នកនាំចេញអង្ករ សហគមន៍កសិករ សមាគមម្ចាស់រោងម៉ាស៊ីនកិនស្រូវ របស់ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ ល ។ ក្នុងរយៈពេលចុងក្រោយនេះ ក៏មានក្រុមហ៊ុនថ្មីៗចូលសមាជិក ស.អ.ក បន្ថែមទៀត ដែលចំនួនសរុបមកដល់បច្ចុប្បន្នមាន៖ **២៤៤** ។

-Acleda Bank Plc
-Allian of Rice Producers and Exports of Cambodia
-AMRU Rice (Cambodia)Co., LTD
-Angkor Kasekam Roong Roeung Co.,Ltd
-ANZ Royal Bank (Cambodia)., Ltd
-Apsara Rice (Cambodia) Co.,Ltd
-Asia Diamond Rice Import Export Co., Ltd
- BAITANG (KAMPUCHEA) Plc.
-Battambang Rice Investment Co.,Ltd
-Bayon Cereal Co.,Ltd
-Boost Riche(Cambodia)Co.,Ltd
-Boromey Vuthy Rice Miller
-Bou Sokha Rice Mill
-Bou Sokkhai Rice Mill
-Bun Hor Rice Mill
-BVB(Cambodia) Agriculture Development Co.,Ltd
-C.H.Y.N Rice Import Eport Co.,Ltd
-Cambodian Rice Exports Assocation
-Canadia Bank Plc
-Capital Food Investment Import Export Co.,Ltd
-Carma Rice Limited
-CaviFoods Company Co.,Ltd
-Chaing Korn Meng
-Chamroeun Chey Agriculture Community
-Chan Kok Lun rice Mill
-Chao Lor Suong Rice Mill
-Chao Seav Rice Mill
-Chea Hap Rice Mill
-Cheav Khouy Rice Mill
-Chhan Nguon Hong Rice Mill
-Chheang Heng Rice Mill
-Chheung Bun Ham Rice Mill
-Chhith Bounthan Rice Mill
-Chhorng Din Rice Mill
-Chhueng Born Rice Mill
-Chhun Thom Rice Mill
-Chhuon Vorn Rice Mill
-CHIEF (Cambodia) Specialized Bank Plc
-Chin Van Rice Mill
-Chouk Tep Rice Mill
-Chrou Thol Rice Mill
-Chum Lay Rice Mill
-Chuoy Sam Rice Mill
-ChyKraeng Sammky Agriculture Development Community
-CK Rice Trading Co., Ltd
-Crystal Rice (Kampuchea) Co., Ltd
-CWT Commodities (Cambodia) Co.,Ltd
-Domnak Teuk Group Co., Ltd
-EangHeang Import Export Co., Ltd
-Ear Chhaiy Yin Rice Mill
-Eath Leangseng Rice Mill
-Eng Hok Rice Mill
-Eng Sorng Rice Mill
-Eng Sour Rice Mill
-Eng Van Mao Rice Mill
-Export Trading Commodities (Cambodia) Limited
-Fang Ly Rice Mill
-Fang Vun Rice Mill
-Fang Vy Rice Mill
-Federation of Associations For Small and Medium Enterpaises of Cambodia
-Golden Daun Keo Rice Mill Co.,Ltd
-Golden Rice (Cambodia) Co.,Ltd
-Golden Star Rice Mill and Import Export Co.,Ltd (Pkay Meas Rice Mill)
-Green Trade Company
-Hang Pi Phally Sokha Rice Mill
-Hay Chuong Rice Mill
-Heng Heang Rice Mill
-Heng Horm Rice Mill
-Heng Huch Rice Mill
-Heng Lay Rice Mill
-Heng Sambath Rice Mill
-Heng Seang Hak Rice Mill
-Hoeng Siva Rice Mill
-Hong Ly Rice Mill
-Hot Ngun Hong Rice Mill
-Hout Chheng Ngoun Rrice Mill
-HS Rice Co.,Ltd
-Huong Leng Rice Mill
-Huong Long Rice Mill
-Huot Ching Rice Mill
-Huy Eang Rice Mill
-Im Eangkry Co.,LTD
-Indochina Rice Mill Limited
-International Rice Trading (Cambodia) Co.,LTD
-Jasmine Rice Mill Factory Co., Ltd
-Jing Mi Rice Mill Co.,Ltd
-Ka Vannara Rice Mill
-Kampongthom Rice Mill Limited
-Kao My Rice Mill
-Kao Nget Rice Mill
-Keat Sothea Rice Mill
-Khean Kav Rice Mill
-Kheng Hout Rice Mill
-Khieu Techsreang Rice Mill
-Khiev Khea Rice Mill
-Khiev Khean Rice Mill
-Khmer Foods Group Co., Ltd
-Khun Nguon Rice Export Co.,Ltd
-Khuth Thanh Rice Mill
-Khy Thay Corperation Co., Ltd
-Kim Se Rice Mill
-Kim Sun Rice Mill
-Kim Ty Rice Mill
-Kong Hour Rice Mill import export Co., LTD
-Krabao Promtep Agriculture Development Community
-Laov Fak Rice Mill
-City Rice Import Export Co.,Ltd
-Ley Chhunh Rice Mill
-Lim Chhunly Rice Mill
-Lim Heng Leap Trading Co.,Ltd
-Lim Kheang Hout Import Eport Co.,Ltd
-Loeung Chhoy Rice Mill
-Lon Cheng Leang Rice Mill

-Long Chhengmeng Rice Mill
-Lor Eak Heng Sek Meas Rice Co.,Ltd
-Loran Group (PLC)
-Luon Kun Rice Mill
-Ly Chhean Rice Mill
-Mao Kuch Rice Mill
-Mao Siphorn Rice Mill
-Meas Chheng Rice Mill
-Mega Green IMEX Cambodian Co., Ltd
-Mekong Oryza Trading Co.,Ltd
-Men Sarun Import Export & Construction Co.,Ltd
-Mom Sophal Rice Mill
-Muoy Leang Rice Mill
-Neng Po Rice Mill
-Ngauv Huong Rice Mill
-Ngeap Chiv Rice Mill
-Ngin Beang Rice Mill
-Ngov Meng Rice Mill
-Nhek Sarith Rice Mill
-Niko Line Investment Co.,Ltd
-Norm Srim Rice Mill
-Om Seth Than Rice Mill
-Pen Narom Rice Mill
-Penh Sovanna Roth Rice Mill
-Pheak Chhuoy Rice Mill
-Phou Poy Develpment Import Export Co.,Ltd
-Phour Kok Ky Rice Mill
-Phum Yerng Agriculture Development Community
-Pidor Ta Ung Agriculture Development Community
-Pon Loeu Kasekor Agricutural Cooperative
-Pov Kea Import Eport Co.,Ltd
-Pov Thouv Rice Mill
-Preah Sihanouk Agriculture Development community
-Professional Package Service
-QC Rice Co., Ltd
-Ram Sar Steung Traeng Rice Development
-Reak Chamroeun Agriculture Development Community
-Ros Hour Rice Mill
-Ruos Neng Rice Mill
-SAHAKREAS CEDAC LTD
-Sann & Khan Rice Mill
-Sann Ty Rice Mill
-Sao Hak Se Rice Mill
-Satrey Haong Samnam Agriculture
-Development Community
-Se Khorn Rice Mill
-Sen Rith Rice Mill
-Seng Bunsor Rice Mill
-Senh Chhinh Rice Mill
-Siev Heng Rice Mill
-Siev Lay Rice Mill
-Signatures of Asia Co.,Ltd
-Smach Kompong Ror Agriculture Development Community
-Sok Keo Import Export Co.,Ltd
-Sok Kong Rice Mill
-Soma Group Co., Ltd
-Sombo Meanchey Agriculture Community
-Song Heng Rice Mill
-Sor Kimsuong Rice Mill
-Sour Kheang Rice Mill
-SSCorp (Cambodia) Ltd
-Suon Sophal Rice Mill
-Suy Vanni Rice Mill
-Svay Meanhey Satrey Sammaky Community
-T.O.T (Trust Our Trade) Co.,LTD
-Ta Kol Yiv Pov Rice Mill
-Taing Cheng Rice Mill
-Takbey Lay Kongveng Rice Mill
-Tauch Tepich Import Export Co., Ltd
-Teav Heu Rice Mill
-Tech Soon Agro- Industry Co.,Ltd
-Thean Kong IMPEX
-The Federation of Cambodia Rice Exporters
-Thmor Korl Rice Import Export Co.,Ltd
-Thol Sam At Rice Mill
-Thorn Chea Rice Mill
-Tiv Eang Rice Mill
-Tong Pheap Rice Mill
-Touch Sarom Rice Mill
-Trapaing Russey Agriculture Development Community
-Ty Chay Rice Mill
-Udom Sorya Agricultural Community
-Ung Huy Meang Rice Mill
-Ung Simon Rice Mill
-UNI – Natural Co.,Ltd
-Vann Linh Vou Rice Mill
-Vibol Dara Rice Mill
-Vong Bun Heng Rice Co., Ltd
-Vong Bun Heng Rice Mill
-W.K.R. Trading Co., Ltd
-White Gold Import Export Co., Ltd
-Ya Rina Rice Mill Siemreap
-Yam Bunsong Rice Mill
-Yam Chanray Rice Mill
-Yam Kinh Rice Mill
-Yam Sann Rice Mill
-Yi Pov Rice Mill
-Yin Khuong Rice Mill
-Yin Mann Rice Mill
-Yin Pou Rice Mill
-You Khim Rice Mill
-AQIP SEED Co.,Ltd
-CMA CGM Cambodia Co.,Ltd
-First Packaging Partner Co., Ltd
-H.L.E.D Trading Co.,Ltd
-Jamson Pest Management
-NOYAKONG Group Co., Ltd
-SMCG Rice Co., Ltd

*សមាជិកថ្មីរួមមាន៖

-365 Moving Co.,Ltd
-7NG UNIOn RICE Co.,Ltd
-BRIGHTWAY GROUP CO.,LTD
-Cam Chin Xin Xi Group Co.,Ltd
-CCIC (Cambodia)
-E-Freight Solution Inc
-Eng Dypo Aphivath Co.,Ltd
-FEDRICE BATTAMBANG LTD
-FELCRA (Cambodia) PTE Ltd
-Great & Grain Garment Asia Pacific(
-Cambodia) Co.,Ltd
-High Level Logistics (Cambodia) C.,Ltd
-Hung Hiep (Cambodia) Co.,Ltd
-Meas Sor (Kampuchea) Co.,Ltd
-MEI JING RICE (CAMBODIA) Co.,Ltd
-Mekong Agro (KH) Industries Limited
-Milin Rice (Cambodia) Import Export Co.,Ltd
-Olam Cambodia
-PALM RICE CO.,LTD
-R.L Co.,Ltd
-SAMBATHVATHANAK Co.,Ltd
-SAMBO RICE CO.,LTD
-SCAFCO CORPORATION (dba SCAFCO
-GRAIN SYSTEMS COMPANY
-SGS (Cambodia) Limited
-TUV Rheinland (Cambodia) Co.,Ltd

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខរួមមាន៖

១. ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត នឹងប្រារព្ធធ្វើនៅថ្ងៃទី ១៣ ដល់ ១៦ ខែមេសា ឆ្នាំ ២០១៦

២. THAIFEX-World Food will be held on 25th to 29th May 2016 in Bangkok, Thailand.





www.worldoffoodasia.com
THAIFEX-
World of food
ASIA
Experience the
Best
in Asia
25. - 29.05.2016
IMPACT Exhibition Center Hall 1-4 NEW
IMPACT Challenger Hall 1-3
IMPACT Exhibition and Convention Center
Bangkok, Thailand
International Trade Exhibition for
Food & Beverages, Food Technology
and Retail & Franchise in Asia
World of SEAFOOD
World of COFFEE &TEA
World of FoodService
Endorsed by
ufi Approved Event
Jointly organized by
The Thai Chamber of Commerce
DITP
Department of International Trade Promotion
Ministry of Commerce, THAILAND
koelnmesse
we energize your business | since 1924

# ស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជា

សហព័ន្ធស្រូវអង្ករកម្ពុជា
**CAMBODIA RICE FEDERATION (CRF)**
# 2C, St. 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia
Web: www.crf.org.kh, Email: info@crf.org.kh

## ស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជាប្រចាំខែ មីនា ឆ្នាំ ២០១៦

## CAMBODIA RICE EXPORT STATISTIC REPORT FOR MARCH 2016

### តារាងទី១/ បរិមាណអង្ករនាំចេញសរុបតាមខែរបស់កម្ពុជាប្រចាំឆ្នាំ ពីឆ្នាំ ២០០៩

**Table 1/ Quantity by month of annual Cambodia Rice Export from 2009**

| Nº | Month/Year | Year-Export (Tons) | | | | | | | | Monthly Variation |
|---|---|---|---|---|---|---|---|---|---|---|
| | | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | (2016 /2015) |
| 1 | មករា - January | 360 | 10,012 | 6,798 | 9,703 | 25,726 | 21,536 | 35,921 | 44,033 | 22.60% |
| 2 | កុម្ភៈ - February | 792 | 13,644 | 5,089 | 14,417 | 24,089 | 27,037 | 37,676 | 51,912 | 37.79% |
| 3 | មីនា - March | 1,248 | 5,062 | 12,534 | 12,310 | 45,413 | 35,758 | 75,867 | 66,275 | -12.64% |
| 4 | មេសា - April | 664 | 17,287 | 17,946 | 15,036 | 23,276 | 35,960 | 51,719 | | |
| 5 | ឧសភា - May | 399 | 5,499 | 20,520 | 13,115 | 28,350 | 27,971 | 41,842 | | |
| 6 | មិថុនា - June | 316 | 4,274 | 17,990 | 13,426 | 29,105 | 29,666 | 40,800 | | |
| 7 | កក្កដា - July | 226 | 15,030 | 12,703 | 20,527 | 31,411 | 26,060 | 28,492 | | |
| 8 | សីហា - August | 673 | 5,997 | 20,404 | 15,530 | 29,358 | 29,871 | 29,819 | | |
| 9 | កញ្ញា - September | 956 | 4,744 | 14,384 | 15,169 | 29,395 | 35,511 | 26,969 | | |
| 10 | តុលា - October | 2,964 | 6,078 | 19,067 | 16,967 | 29,031 | 35,418 | 39,064 | | |
| 11 | វិច្ឆិកា - November | 1,690 | 7,988 | 9,559 | 25,189 | 37,855 | 31,137 | 48,748 | | |
| 12 | ធ្នូ - December | 2,325 | 9,645 | 44,905 | 31,328 | 46,847 | 51,136 | 81,479 | | |
| | **សរុប -Total** | **12,613** | **105,260** | **201,899** | **202,717** | **379,856** | **387,061** | **538,396** | **162,220** | |

### តារាងទី២/ បរិមាណតាមប្រភេទអង្ករនាំចេញរបស់កម្ពុជា គិតជាតោន

**Table 2/ Quantity of Cambodian Rice Export by Type of Rice, in Tones**

| Nº | Year-Export (Tons) | TYPES OF RICE | | | | |
|---|---|---|---|---|---|---|
| | | Premium Fragrant Rice | Fragrant Rice | Long Grain White rice | Long Grain Paboiled Rice | Total Qty |
| 1 | **2013** | 178,190 | 6,664 | 194,004 | - | **378,858** |
| 2 | **2014** | 170,819 | 61,966 | 135,226 | 19,050 | **387,061** |
| 3 | **2015** | 186,758 | 87,913 | 221,862 | 41,863 | **538,396** |
| **Month-Export (Tons) in 2016** | | | | | | |
| 1 | **January** | 15,086 | 7,937 | 18,755 | 2,255 | **44,033** |
| 2 | **February** | 9,367 | 13,809 | 25,366 | 3,370 | **51,912** |
| 3 | **March** | 8,128 | 18,017 | 33,988 | 6,142 | **66,275** |
| **សរុប-Grand Total by Type in 2016** | | **32,581** | **39,763** | **78,109** | **11,767** | **162,220** |







CRF_March.2016

Sourced: SOWS-REF




# CONNECT

WITH THE BANK THAT'S BEEN

# SUPPORTING CUSTOMERS

FOR 180 YEARS

As a customer of ANZ's super regional network, you can now capitalise on the stability and expertise of one of the safest banks in Asia Pacific. Because of our commitment to the highest banking standards, we've been consistently recognised for our long-term creditworthiness and strength:

- Voted Best Trade Finance Bank in Cambodia by Global Finance Magazine[1]
- Cambodia's Bank of the Year[2]
- Top 4 Corporate Bank in Asia by Greenwich Associates[3]
- One of the world's top 25 banks by market capitalisation[4]
- Ranked 19 on Global Finance Magazine's World's 50 Safest Banks[5]
- Over 10 million customers around the world

023 999 000

With a network that spans across 29 markets in Asia Pacific, you can now have access to more financial expertise that connects you to the right products, the right people and the right opportunities. And our significant financial assets ensure that we are well-positioned to support your individual or business lending requirements so as to reach your goals.

With ANZ Royal, you'll have a reliable partner who can take care of all your financial needs, wherever you need it.

1 Global Finance Magazine 2015 2 The Banker magazine, Bank of the Year Awards 2006, 2011 and 2013
3 Source: Greenwich Associates Asian Large Corporate Banking Survey 2013 4 Based on market capitalisation
5 As at September 2014

anzroyal.com

ANZ Royal
YOUR WORLD, YOUR WAY

នីកូលីន អ៊ិនវេសមេន ខូ., អិលធីឌី

NIKOLINE INVESTMENT CO., LTD

## NIKOLINE RICE MILL

- Established in 2010 and continue to provide only the best quality rice from Cambodia.
- Cap: 50,000Mt/year
- Products:
    - **JASMINE RICE**
    - **FRAGRANT RICE (SEN KRA OB)**
    - **LONG GRAIN WHITE RICE**
    - **Brown Rice BROWN RICE**
- Packaging:
    + 1 - 10kg (Vacuumed & Non vacuumed)
    + 10 - 50kg PP or PP+PE Bag
    + Jumbo & Liner Bag








**CONTACT:**

**Mr. NORNG VEASNA,** Director of Sales, Mobile: (+855) 12 400 112 (available on what's app & LINE), rice.veasnanorng@gmail.com

**Mr. HONG NIKOLINE,** Mobile: (+855) 77 777 708 Email: nikoline@nklrice.com

**Mr. VINH CHEANG,** Mobile: (+855) 12 933 737 Email: v.cheang7ricemill@gmail.com

**PHNOM PENH Office:** #17, Street 334, Sangkat Beoung Kengkang 1, Khan Chamkamorn, Phnom Penh, CAMBODIA

**Mill:** Veal Kangdeang Village, Chup Commune, Tboung Khmum District, Tboung Khmum Province, CAMBODIA

**Visit us: www.nikoline.com.kh**



ផ្សព្វផ្សាយ និងបោះពុម្ពដោយ៖

គាំទ្រដោយ៖

CDC

អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧ អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី ॥ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

គេហទំព័រ៖ www.crf.org.kh / Facebook Page: https://www.facebook.com/cambodiaricefederation

សារអេឡិចត្រូនិក៖ info@crf.org.kh ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩